# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២៤
# របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា



វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

រាជធានីភ្នំពេញ ឆ្នាំ២០២៥

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២៤

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលហៅកាត់ថា ***វ.ស.ក.ក*** បានបង្កើតនៅឆ្នាំ១៩៥៥ ដោយសមាគមអ្នកដាំកៅស៊ូនៅកម្ពុជា។ នៅឆ្នាំ ១៩៧០-១៩៩០ សកម្មភាពស្រាវជ្រាវរបស់ ***វ.ស.ក.ក*** ត្រូវបានផ្អាកដោយប្រទេសមានសង្គ្រាម ហើយត្រូវបានបង្កើតឡើងវិញដោយប្រកាសលេខ១០៣១.៣៧០ចត.២ខ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩១ និងក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២។ នៅឆ្នាំ២០០១ ***វ.ស.ក.ក*** បានចូលជាសមាជិកទី១៦ របស់ របស់ IRRDB។ ***វ.ស.ក.ក*** ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ និងត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធយ៉ាងទូលំទូលាយដើម្បីបំពេញបេសកកម្មក្នុងនាមជាវិទ្យាស្ថាន ក្នុងក្របខណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យ និងបទបញ្ជារផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងគ្រប់គ្រងដោយនាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការ។ ***វ.ស.ក.ក*** មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។

***វ.ស.ក.ក*** មានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពការងារស្រាវជ្រាវប្រចាំឆ្នាំ២០២៤ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះ បង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់អង្គភាពចំណុះរបស់ខ្លួនរួមមាន ការបង្កាត់ពូជ ការដាំដុះនិងការពារ សរីរវិទ្យានិងអាជីវកម្ម មន្ទីរពិសោធន៍ជាតិយថាប្រភេទ ស្ថានីយពិសោធន៍ ព្រមទាំងអង្គភាពពាក់ព័ន្ធមួយចំនួនទៀតរបស់ ***វ.ស.ក.ក***។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិក និងថ្នាក់ដឹកនាំ ***វ.ស.ក.ក*** ទាំងអស់ នៅក្នុងការពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្តាដៃគូអន្តរជាតិផ្សេងទៀតមានដូចជា៖ CIRAD, IRRDB, CATAS, HRPP, WWF ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចីរភាព។

របាយការណ៍នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូ រួមទាំងអ្នកនយោបាយ អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ គ្រូបង្រៀន និស្សិត និងអាចទាំងកសិករទៀតផង។ សម្រាប់វិទ្យាស្ថានផ្ទាល់ របាយការណ៍នេះជាការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ខ្លួនឲ្យបន្តខិតខំស្រាវជ្រាវដើម្បីសម្រេចនូវបេសកកម្មក្នុងកិច្ចការស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យានៅកម្ពុជា។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះជាប្រភពព័ត៌មានដ៏មានសារៈសំខាន់សម្រាប់គ្រប់ស្រទាប់អ្នកប្រើប្រាស់។

ថ្ងៃ ចន្ទ ៦កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥

**នាយក**

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

# មាតិកា

ទំព័រ


អារម្ភកថា ........ ii
១. សេចក្តីផ្តើម ........ ១
២. អង្គការលេខ និងស្ថានភាពបុគ្គលិក ........ ២
២.១. អង្គការលេខ ........ ៣
២.២. ស្ថានភាពបុគ្គលិក ........ ៤
៣. ព្រឹត្តិការណ៍សំខាន់ៗ និងការគ្រប់គ្រង ........ ៤
៤. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករសមិទ្ធិកម្មឆ្នាំ២០២៤ ........ ៥
៥. សមិទ្ធផលនៃការស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងឆ្នាំ២០២៤ ........ ៦
៥.១. ចង្កោមសកម្មភាពទី១.៥.១ ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ ........ ៦
៥.១.១. ចំនួនតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ (ដង) ........ ៦
៥.១.២. ចំនួនតេស្តប្រៀបធៀបមន្ទីរពិសោធន៍ (ដង) ........ ៦
៥.១.៣. ការធ្វើតេស្តនិងគុណភាពកៅស៊ូ (CSR) (ដង) ........ ៦
៥.២. ចង្កោមសកម្មភាពទី១.៥.២ ពង្រឹងការពិសោធន៍និងការស្រាវជ្រាវដំណាំកៅស៊ូ ........ ៧
៥.២.១. ចម្ការពិសោធន៍បង្កើតនិងតាមដាន (ចម្ការ) ........ ៧
៥.២.២. ចំនួនក្លូនកៅស៊ូ អភិវឌ្ឍនិង អភិរក្ស (ក្លូន) ........ ៧
៥.២.៣. ចំនួនសំណាកទឹកជ័រត្រូវវិភាគសរីរៈសាស្ត្រ (សំណាក) ........ ៧
៥.៣. ចង្កោមសកម្មភាពទី១.៥.៣ ពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ៨
៥.៣.១. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ៨
៥.៣.២. ការពង្រឹងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ........ ៨
៥.៣.៣. ការផ្សព្វផ្សាយបច្ចេកទេស ........ ៨
៥.៣.៤. ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ ........ ៩
៦. សេចក្តីសន្និដ្ឋាន និងសំណូមពរ ........ ១០
៧. ទិសដៅការងារសម្រាប់ឆ្នាំ២០២៥ ........ ១១

## ១. សេចក្តីផ្តើម

ក្នុងបរិបទនៃការលើកស្ទួយវិស័យកសិកម្ម ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាឲ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការបង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមអភិក្រមនិងវិសាលភាពថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងៗទៀត) ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ពោលគឺពឹងផ្អែក ជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី កសិកម្មវៃឆ្លាត ការស្រាវជ្រាវ និងអភិវឌ្ឍយូបនីយកម្ម ព្រមទាំងការ បង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សាររួមទាំងការ ចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្មក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិទី៧ ផែនការសកម្មភាពជាតិ ស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៩-២០២៣ ទិសដៅគោលនយោបាយរួមសំដៅ (១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្មនិង (២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ក្នុងបរិបទនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ និងមានចក្ខុវិស័យ «កសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសាកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា»។ ដើម្បីជំរុញកំណើនផលិតកម្មគ្រប់មុខក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់ ៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម ៧% ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាពពិពិធកម្មដំណាំដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកំពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្ម តាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកប ដោយនិរន្តរភាព។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (**វ.ស.ក.ក**) ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រគល់ភារកិច្ច ឲ្យស្ថិតនៅក្នុងកម្មវិធីទី១ គឺ៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច។ **វ.ស.ក.ក** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំតម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ ដែល **វ.ស.ក.ក** ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធីទី១ និងអនុកម្មវិធីទី៥ ស្តីអំពី៖ «ការលើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ» ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន៣គឺ៖ ១.៥.១. ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាពនិងការពង្រឹងគុណភាពផលិតផលកៅស៊ូ ១.៥.២. ពង្រឹងការពិសោធន៍និងការស្រាវជ្រាវដំណាំកៅស៊ូ ១.៥.៣. ពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗ របស់ វ.ស.ក.ក ឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៩-២០២៣ ហើយនឹងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់ វ.ស.ក.ក ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធីដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែមទៀត បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ នឹងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

## ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

### ២.១. អង្គការលេខ

**វ.ស.ក.ក** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមរយៈអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារដូចតទៅ៖ **វ.ស.ក.ក** មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែកនៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញផ្នែកបច្ចេកទេស សុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ **វ.ស.ក.ក** បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូ សំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជាដែលមានសក្តានុពល បន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ក្នុងឆ្នាំ២០២៤នេះ **វ.ស.ក.ក** បានអនុវត្តនិងបន្តការងារស្រាវជ្រាវ ហើយនិងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូដែលជាសរុបមាន៦៤ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ **វ.ស.ក.ក** បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្ស តាមរយៈការបង្ហាត់បង្រៀននិស្សិត នៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឲ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍ និងការដឹកនាំសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។ នៅក្នុងអនុក្រឹត្យ **វ.ស.ក.ក** មានកាតព្វកិច្ចចំនួន ០៨ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើងសំដៅលើការអនុវត្តឲ្យបានសម្រេច ឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ **វ.ស.ក.ក** តាមរយៈប្រកាសលេខ៥៧៦ ប្រក.កសក.ប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ **វ.ស.ក.ក** មានការិយាល័យ និងអង្គភាពចំណុះចំនួន ០៧ រួមមាន៖

១- ការិយាល័យ រដ្ឋបាល និងបុគ្គលិក

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យ បង្កាត់ពូជ

៤- ការិយាល័យ ដាំដុះ និងការពារ

៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម

៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ

៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

## អង្គការលេខវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Cambodian Rubber Research Institute Organization




***យោង៖*** *-អនុក្រឹត្យលេខ១៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល*

*-អនុក្រឹត្យលេខ១៦៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ១៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧*

## ២.២ ស្ថានភាពបុគ្គលិក

មន្ត្រី *វ.ស.ក.ក* ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤២នាក់ ក្នុងនោះមានស្ត្រី ១៣នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប ២៨៥នាក់។ មន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៨នាក់ មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ១០នាក់ |
| + បរិញ្ញាបត្រ | ២៧នាក់ |
| + មធ្យមបច្ចេកទេស | ០២នាក់ |
| + បឋមឯកទេស | ០២នាក់ |
| និងមន្ត្រីជាប់កិច្ចសន្យា | ២០នាក់ |

## ៣. ព្រឹត្តិការណ៍សំខាន់ៗនិងការគ្រប់គ្រង

បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល *វ.ស.ក.ក.* ក្រោមអធិបតីភាពឯកឧត្តម **ចាន់ សារុន្ធ** អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ *វ.ស.ក.ក.* ដើម្បីពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវកៅស៊ូចំនួន ០៥លើក ព្រមទាំងប្រជុំអចិន្ត្រៃយ៍ និងវិសាមញ្ញរបស់វិទ្យាស្ថានចំនួន១០លើក។

វិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ CIRAD, AFD, CATAS, GDR និង GDA នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានជួបពិភាក្សាការងារជាមួយប្រតិភូ CIRAD អំពីកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវកៅស៊ូ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ច និងការជួបសំណេះសំណាលរបស់ ឯកឧត្តម **ប្រាក់ ដាវីដ** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អមដំណើរដោយ ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការ កសក និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ។

ឯកឧត្តម **ចាន់ សារុន្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចុះពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវនៅស្ថានីយ៍ពិសោធន៍ វ.ស.ក.ក។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ច និងការជួបសំណេះសំណាលរបស់ ឯកឧត្តម **គី ច័ន្ទរំដួល** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះពិនិត្យវឌ្ឍភាពការងារស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ច លោកជំទាវ **អ៊ឹម រចនា** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថតវីដេអូផ្សព្វផ្សាយ អំពីការអភិវឌ្ឍ អនុវិស័យកៅស៊ូ។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ច លោក **Stephane Boulakia** អ្នកជំនាញពី CIRAD ចុះសិក្សាស្តីអំពីការព្យាករណ៍ផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុរបស់គម្រោង FORSEA ។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ចគណៈប្រតិភូមកពីនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មចុះទស្សនកិច្ចសិក្សាពីការអនុវត្តបច្ចេកទេសផលិតកម្មដំណាំគម្របដីនៅក្នុងចម្ការកៅស៊ូ

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលនិស្សិតសាលាជាតិកសិកម្មកំពង់ចាមចុះទស្សនកិច្ចសិក្សាលើខ្សែច្រវាក់ផលិតកម្មកៅស៊ូ។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គនាយកដ្ឋានកៅស៊ូ (GDR) និងមន្ត្រី CIRAD ចុះទស្សនកិច្ចសិក្សាស្វែងយល់ពីការងារស្រាវជ្រាវកៅស៊ូនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**វ.ស.ក.ក** បានរៀបចំការបណ្តុះបណ្តាលបច្ចេកទេសស្តីពីកសិរុក្ខកម្មកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារចំនួន៤៧នាក់(ស្រី២០នាក់) ដែលអញ្ជើញមកពីស្រុកពេជ្រាដា និងស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី។

## ៤. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករសមិទ្ធិកម្មឆ្នាំ២០២៤

ក្នុងរយៈពេលមួយឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលផ្នែកបច្ចេកទេស និងការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមទាំងក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាល រួមទាំងកិច្ចសហការពីថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **វ.ស.ក.ក** ហើយជារួមសមិទ្ធផលក្នុងឆ្នាំ២០២៤ វ.ស.ក.ក សម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ ស្របទៅតាមសូចនាករដែលបានព្យាករណ៍ទុកដូចមានបង្ហាញក្នុងតារាង១។

**តារាង១** លទ្ធផលឆ្លើយតបទៅនឹងសូចនាករដែលបានព្យាករណ៍ក្នុងផែនការឆ្នាំ ២០២៤

| សូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅប្រចាំឆ្នាំ | លទ្ធផលសម្រេចបានមកដល់បច្ចុប្បន្ន | % នៃគោលដៅសម្រេចបាន |
|---|---|---|---|
| ចង្កោមសកម្មភាពទី ១.៨.១ ការសិក្សា និងអនីវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ | | | |
| -ចំនួនតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ (ដង) | ០២ | ០២ដង | ១០០% |
| -ចំនួនតេស្តប្រៀបធៀបមន្ទីរពិសោធន៍ (ដង) ក្នុងស្រុក | ០ ២ | ០២ដង | ១០០% |
| -ការធ្វើតេស្តនិងគុណភាពកៅស៊ូ (CSR) (ដង) | ០៤ | ០៤ដង | ១០០% |
| -ការចុះបញ្ជិកា ទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា | | ០៥រោងចក្រ/ ០៣មន្ទីពិសោធន៍ | |
| ចង្កោមសកម្មភាពទី ១.៨.២ ពង្រឹងការពិសោធន៍និងការស្រាវជ្រាវដំណាំកៅស៊ូ | | | |
| -ចម្ការពិសោធន៍បង្កើតនិងតាមដាន (ចម្ការ) | ៦៤ | ៦៤ | ១០០% |
| -ចំនួនក្លូនកៅស៊ូ អភិវឌ្ឍនិង អភិរក្ស (ក្លូន) | ៧៨ | ៧៨ | ១០០% |
| -ចំនួនសំណាកទឹកជ័រត្រូវវិភាគសរីរៈសាស្ត្រ (សំណាក) | ៥៨០ | ១៦២៨ | ២៨០% |
| ចង្កោមសកម្មភាពទី ១.៨.៣ ពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | |
| - ចំនួនផ្ទះកម្មករដែលត្រូវកែលម្អ (ខ្នង) | ២៥ | ២៥ | ១០០% |
| - សាងសង់របងក្នុងស្ថានីយពិសោធន៍ (ម៉ែត្រ) | ១០០០ | ១០០០ | ១០០% |

## ៥. សមិទ្ធផលនៃការស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤ ក៏ដូចបណ្តាឆ្នាំមុនៗកន្លងមកដែរ ***វ.ស.ក.ក*** បានខិតខំបន្តអនុវត្តការងារពិសោធន៍ និងស្រាវជ្រាវឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍ ដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត ***វ.ស.ក.ក*** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចជា (១)ផ្នែកក្សេត្រសាស្ត្រ៖ ការងារដាំដុះនិងការពារ, ការងារបង្កាត់ពូជ, ការងារសរីរសាស្ត្រនិងអាជីវកម្ម។ (២)ផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ និង(៣)ការបណ្តុះបណ្តាលការផ្សព្វផ្សាយចំណេះបច្ចេកទេសនិងព័ត៌មានកៅស៊ូដល់ប្រតិបត្តិករ សមាគម និងកសិករ។ ជារួមវិទ្យាស្ថានបានធ្វើពិសោធន៍ទាំងក្នុង និងក្រៅស្ថាននីយ៍បានលទ្ធផលទៅតាមគោលបំណងនិងសូចនាករក្នុងចង្កោមកម្មវិធីសកម្មភាពទាំង០៣ តាមលំដាប់លំដោយដូចខាងក្រោម៖

### ៥.១. ចង្កោមសកម្មភាពទី១.៥.១ ការសិក្សា និងអនីវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ

គោលបំណងសំខាន់នៃចង្កោមសកម្មភាព១.៥.១គឺ សំដៅធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលយថាប្រភេទកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ដើម្បីទទួលបាននូវតម្លៃសមស្រប បង្កើនចំណូលដល់អ្នកដាំដុះកៅស៊ូ និងជំរុញនូវកំណើនសេដ្ឋកិច្ចសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួន០៣ត្រូវបានដាក់ចេញដូចខាងក្រោម៖

**៥.១.១. ចំនួនតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍** (**ដង**)៖ បានធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្រៅស្រុក (Round Robin Crosscheck) បានចំនួន០២លើក គឺការធ្វើតេស្តលើកទី១៣០ និងការធ្វើតេស្តលើកទី១៣១ ជាមួយសមាគមកៅស៊ូអន្តរជាតិ International Rubber Association (IRA)។

**៥.១.២ ចំនួនតេស្តប្រៀបធៀបមន្ទីរពិសោធន៍** (**ដង**)៖ បានធ្វើតេស្តប្រៀបធៀប អន្តរមន្ទីរពិសោធន៍ក្នុងស្រុកចំនួន ០២លើក(លើកទី៦៦និង៦៧) ដែលមានចំនួន១២មន្ទីរពិសោធន៍មូលដ្ឋាន បានចូលរួមធ្វើតេស្ត ដើម្បីពង្រឹងគុណភាព និងការគ្រប់គ្រងមន្ទីរពិសោធន៍មូលដ្ឋាន។

**៥.១.៣. ការធ្វើតេស្តនិងគុណភាពកៅស៊ូ** (CSR) (**ដង**)៖ បានធ្វើតេស្តនិងពិនិត្យគុណកៅស៊ូដុំ(TSR) ចំនួន៤០ សំណាក ព្រមទាំងបានធ្វើតេស្តកៅស៊ូសន្លឹក(RSS) របស់ ***វ.ស.ក.ក***. សរុបចំនួន៧២សំណាក។ **ការចុះបញ្ជិកាទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា៖** គឺជាការចុះពិនិត្យបណ្តារោងចក្រកែច្នៃយថាប្រភេទកម្ពុជា(CSR) និងយកសំណាកមកធ្វើតេស្តពិនិត្យគុណភាព សំដៅធ្វើការតម្រង់ទិស និងកែលម្អនូវចំណុចខ្វះខាត ដើម្បីលើកកម្ពស់គុណភាពផលិតផលកៅស៊ូកម្ពុជា។ បានចុះបញ្ជិកាទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ជូនរោងចក្របានចំនួន០៥រោងចក្រ និងមន្ទីរពិសោធន៍ចំនួន០៣មន្ទីរពិសោធន៍មូលដ្ឋាន។ ជាលទ្ធផលរោងចក្រកែច្នៃកៅស៊ូ យថាប្រភេទកៅស៊ូកម្ពុជា(CSR)ចំនួន២២រោងចក្រ និងមន្ទីរពិសោធន៍ ចំនួន១២មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវបានទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាពី ***វ.ស.ក.ក***។

ជាលទ្ធផលចុងក្រោយនៃការអនុវត្តចង្កោមសកម្មភាព១.៥.១ គឺការប្រមូលផលកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពចម្ការកៅស៊ូ និងបង្កើនបាននូវប្រសិទ្ធភាពពលកម្ម ហើយនិងវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូត្រូវទទួលស្គាល់ជាអន្តរជាតិ តាមរយៈ IRA ទទួលសិទ្ធចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

### ៥.១. ចង្កោមសកម្មភាពទី១.៥.២ ពង្រឹងការពិសោធន៍និងការស្រាវជ្រាវដំណាំកៅស៊ូ

ចង្កោមសកម្មភាពនេះមានគោលបំណងបង្កើតការគ្រប់គ្រងនិងស្រង់ទិន្នន័យចម្ការពិសោធន៍ ការបង្កាត់ ធ្វើជម្រើស អភិវឌ្ឍក្លូនកៅស៊ូ គ្រប់គ្រងច្បារពូជ អភិវឌ្ឍរុក្ខសម្ភារកៅស៊ូ រៀបចំអនុសាសន៍ក្លូនកៅស៊ូ វិភាគសរីរៈទឹកជ័រធ្វើការផ្លាស់ប្តូរក្លូនកៅស៊ូជាមួយបណ្តាសមាជិក IRRDB ក្នុងការអភិវឌ្ឍក្លូន និងធនធានសេនេទិចកៅស៊ូ និងធ្វើពិពិធកម្មប្រភេទដំណាំចន្លោះរង ដោយយកដំណាំកៅស៊ូជាមូលដ្ឋាន។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើសកម្មភាពចំនួន០៣ត្រូវបានដាក់ចេញ នឹងទទួលលទ្ធផលបានដូចខាងក្រោម៖

**៥.២.១. ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ៖** បានតាមដានស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ចំនួន២១ចម្ការពិសោធន៍ ដែលបានដាំរាយប៉ាយទៅតាមទីតាំងនិងតំបន់ផ្សេងៗដូចជា ១. ស្ថានីយពិសោធន៍នៃ វ.ស.ក.ក. ២.ក្រុមហ៊ុនទ្រីភាពបឹងទន្លេម្រេចខេត្តព្រះវិហារ ៣.ក្រុមហ៊ុនSOCFIN-KCD ខេត្តមណ្ឌលគិរី ៤. ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខេត្តត្បូងឃ្មុំ អនុវត្តការថែទាំច្បារពូជកៅស៊ូទំហំ៨,៦០ហិកតាសម្រាប់បំរើដល់ការពិសោធស្រាវជ្រាវ បានដាំកូនកៅស៊ូក្លូន CRRI 19 ចំនួន៥២៥០ដើម និង CRRI 12 ចំនួន៣៨២៥ដើមក្នុងច្បារពូជថ្មីទំហំមួយហិកតា ចុះអង្កេតការជ្រុះស្លឹកនិងចេញផ្ការនៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦ បានចេញវិញ្ញាបនបត្រច្បារពូជកៅស៊ូចំនួនពីរដល់កសិករកៅស៊ូគ្រួសារ នៅក្នុងស្រុកចម្ការលើខេត្តកំពង់ចាម និងស្រុកតំបែរខេត្តត្បូងឃ្មុំ បានផ្តល់មែកពូជដល់ក្រុមហ៊ុនចម្ការកៅស៊ូមេមត់នូវក្លូនចំនួន២៖ CRRI 19= ៣៥ ម៉ែត្រ CRRI 12=៣៥ ម៉ែត្រ។ មិនតែប៉ុណ្ណោះនៅឆ្នាំ២០២៤ នេះ វ.ស.ក.ក. បានស្នើសុំបញ្ចេញក្លូនកៅស៊ូកម្ពុជា CRRI12 និង CRRI 19 ឱ្យប្រើប្រាស់ជាផ្លូវការទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយទទួលបានវិញ្ញាបនបត្របញ្ចេញប្រភេទពូជដំណាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើក្លូនកៅស៊ូកម្ពុជានេះ។

**៥.២.២. ការងារសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រ៖** តាមដាន ស្រង់ បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយ៍ចំនួន១៧ និងក្រៅស្ថានីយចំនួន៥ (ទំហំដើម ទិន្នផល និងជំងឺស្ងួតមុខចៀរ(TPD)) ចម្ការពិសោធន៍រួមមាន៖ (១) សក្តានុពលទិន្នផល (d3, d4) និងប្រព័ន្ធចង្វាក់ចៀរធ្វើល(d3, d4, d5, d6) (២)ចម្ការពិសោធន៍អំពីប្រព័ន្ធចង្វាក់ចៀរធ្វើល (d3, d4, d5 & d6)នៅក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខេត្តក្រចេះ (៣)ចម្ការពិសោធន៍អំពីប្រព័ន្ធចង្វាក់ចៀរធ្វើល (d4, d6, d8 & d10) នៅក្រុមហ៊ុនចម្ការកៅស៊ូSOCFIN-COVIPHAMA ខេត្តមណ្ឌលគិរី (៤)ការបើកមុខចៀរលើទំហំដើមខុសគ្នា។ ក្នុងឆ្នាំ២០២៤នេះដែរបានបង្កើតចម្ការពិសោធន៍ប្រព័ន្ធចង្វាក់ចៀរធ្វើល (d3, d4, d6, d8 & d10) នៅក្នុងស្ថានីយ៍ពិសោធន៍នៃវិទ្យាស្ថាន ចំពោះការវិភាគសរីរៈទឹកជ័រ (Latex Diagnosis) ក្នុងមន្ទីរពិសោធន៍សរីរវិទ្យាទឹកជ័រ គឺបានយកសំណាកនិងវិភាគសរីរទឹកជ័រពីចម្ការពិសោធន៍នានាក្នុង និងក្រៅស្ថានីយបានចំនួន១៦២៨ សំណាក។

**៥.២.៣. ការងារកសិក្សា-បរិស្ថាន៖** បានរៀបចំចម្ការពិសោធន៍ក្នុងផ្នែកដាំដុះនិងការពារ គឺដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រដាំដុះ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងជីជាតិដី បង្កើនប្រសិទ្ធភាពនៃចម្ការនិងការប្រើប្រាស់ដី បង្កើតនូវចំណូលបន្ថែមតាមរយៈការធ្វើពិពិធកម្មកៅស៊ូជាមួយនិងប្រភេទដំណាំ និងរុក្ខជាតិផ្សេងទៀត។ ១. ទិន្នន័យចម្ការពិសោធន៍ត្រូវបានស្រង់និងវិភាគរួមមាន៖ (I) អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (II)ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ផ្តល់ផល និងកៅស៊ូផ្តល់ផល (III)ការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ (IV)ដំណាំគម្របដី ផលិតកម្មជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (V)ដង់ស៊ីតេដាំដុះដើមកៅស៊ូ (VI)ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់និងទិន្នផលកៅស៊ូ។ ២. អនុវត្តការងារដាំដុះកូនកៅស៊ូលើផ្ទៃដី៨ហិកតាក្លូនRRIM712 និង ៣. រៀបចំថ្នាលបណ្តុះកៅស៊ូកៅស៊ូលើផ្ទៃដី០,៣៥ហិកតា។

### ៥.៣. ចង្កោមសកម្មភាពទី១.៥.៣ ពង្រឹងយន្តការគាំទ្រដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ចង្កោមសកម្មភាពទី១.៥.៣ មានក្នុងគោលបំណងធ្វើការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តុះបណ្តាលធនធានមនុស្ស និងផ្ទេរបច្ចេកវិទ្យា ការចូលរួមពីដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ ការផ្តល់សេវាបច្ចេកទេសគាំទ្រ និងការងារគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

**៥.៣.១. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** សាងសង់ជួសជុលផ្ទះស្នាក់នៅរបស់កម្មករបានចំនួន២៥ខ្នង សាងសង់របងស្ថានីយ៍ប្រវែង១០០០ម៉ែត្រ បណ្តាញទឹក និងបណ្តាញភ្លើងរបស់កម្មករក្នុងភូមិ៣២, ការជួសជុលសាលារៀនសាលាសន្សំកុសលនៅក្នុងភូមិ៣២, ការជួសជុលលាបថ្នាំអាគារការិយាល័យ និងអាគារស្នាក់នៅរបស់មន្ត្រីរាជការនៅក្នុងស្ថានីយ, ការជួសជុលផ្លូវក្នុងចម្ការកៅស៊ូពិសោធន៍របស់ *វ.ស.ក.ក.* និងការរៀបចំសោភ័ណ្ឌភាពនៅមុខអគារការិយាល័យ និងនៅមុខមន្ទីរពិសោធន៍ជាតិយថាប្រភេទក្នុងស្ថានីយ៍។

**៥.៣.២. ការពង្រឹងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស៖** មន្ត្រីនៃ ***វ.ស.ក.ក*** បានចូលរួមបង្រៀននៅសាលាជាតិកសិកម្មកំពង់ចាម ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រដំណាំកៅស៊ូ លើមុខវិជ្ជាផលិតកម្មដំណាំកៅស៊ូ។ មន្ត្រីវិទ្យាស្ថានបានរៀបចំ Poster ស្តីពីក្លូនកៅស៊ូកម្ពុជា CRRI 12 & CRRI 19 ដើម្បីផ្សព្វផ្សាយពីសក្តានុពលក្លូនកៅស៊ូកម្ពុជា បានធ្វើបទបង្ហាញស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ ២០២៣-២០២៥ នៅក្នុងសិក្ខាសាលាវេទិកាពហុភាគី ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានកៅស៊ូ អង្គការ WWF-Cambodia និងអង្គការខាំបូឌ្រា នៅក្រុងកំពង់ចាម បានចំនួន២វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៨៦នាក់(ស្រី១៤នាក់) បានសហការជាមួយអង្គការ WWF-Cambodia និងអង្គការខាំបូឌ្រា រៀបចំវគ្គបណ្តុះបណ្តាលស្តីកសិរុក្ខកម្មកៅស៊ូ នៅក្រុងកំពង់ចាម បានចំនួន១វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥៧នាក់(ស្រី២១នាក់) បានរៀបចំបទបង្ហាញបច្ចេកទេសខ្លី (Poster) ចំនួន៦ក្នុងកម្មវិធីទស្សនកិច្ចសិក្សានៃសិក្ខាសាលាគម្រោង FORSEA នៅស្ថានីយ៍ពិសោធន៍នៃ វ.ស.ក.ក បានរៀបចំទទួលប្រតិភូចំនួន៤៩នាក់មកពីអគ្គនាយកដ្ឋានកសិកម្មមកទស្សនកិច្ចសិក្សានៅស្ថានីយពិសោធន៍ មន្ត្រី វ.ស.ក.ក. ២រូប បានទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកវិទ្យាកៅស៊ូដែលរៀបចំឡើងដោយ IRRDB និងបានចូលរួមសន្និសីទកៅស៊ូអន្តរជាតិ (IRC 2024) នៅប្រទេសថៃនិង(IRC 2024) នៅប្រទេសឥណ្ឌូណេស៊ី មន្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗនៅក្រៅប្រទេសចំនួន០៥លើក មានអ្នកចូលរួម០៧នាក់។

**៥.៣.៣. ការផ្សព្វផ្សាយបច្ចេកទេស៖** បានទទួលនិស្សិតនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ជំនាញក្សេត្រសាស្ត្រចំនួន០៦រូប និស្សិតស្រីចំនួន០៥រូប និងប្រុសចំនួន០១រូបដែលកំពុងសិក្សាលើមុខវិជ្ជា ផលិតកម្មដំណាំកៅស៊ូ ដើម្បីចុះទស្សនកិច្ចសិក្សា នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**៥.៣.៤. ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ៖** ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា ***វ.ស.ក.ក*** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការអន្តរជាតិជាច្រើនរួមមាន៖

❖ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

ជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា។

នៅឆ្នាំ២០១៦ ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្ដីអំពី "***និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមានគណៈប្រតិភូពីបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុប ចំនួន៣៣០នាក់។ នៅឆ្នាំ២០១៧ ***វ.ស.ក.ក*** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្ដីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ ដោយមានភ្ញៀវពី បណ្ដាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺៈ *កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី* អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

នៅឆ្នាំ២០២៤ វ.ស.ក.ក បានចូលរួមសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០២៤និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិចំនួន២លើកដែលបានប្រព្រឹត្តទៅនៅប្រទេសថៃនិងប្រទេសឥណ្ឌូនេស៊ី។

❖ **កិច្ចសហប្រតិបត្តិការជាមួយ CIRAD**

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ ***វ.ស.ក.ក*** បានធ្វើសហប្រតិបត្តិការជាមួយ *មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍន៍ (CIRAD)* នៃប្រទេសបារាំង លើការងារស្រាវជ្រាវផ្នែក ក្សេត្យសាស្ត្រ បង្កាត់ពូជ ការប្រមូលផលជ័រនិងសរីរសាស្ត្រទឹកជ័រ ជាមួយជំនាញការនៃមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិ ដើម្បីអភិវឌ្ឍកសិកម្ម (CIRAD)។ ជំនាញការCIRAD ម្នាក់បានមកប្រចាំការនៅវិទ្យាស្ថាន។

❖ **កិច្ចសហប្រតិបត្តិការជាមួយ CATAS**

កិច្ចសហប្រតិបត្តិការរវាង ***វ.ស.ក.ក*** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើងលើការងារស្រាវជ្រាវកៅស៊ូរួមគ្នាជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS)។ មន្ត្រីជំនាញពី CATAS ចំនួន៤រូបបានសហការជាមួយមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានចុះអង្កេតពីការប្រើប្រាស់ក្លូនកៅស៊ូនៅតាមបណ្ដាខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា។

❖ **កិច្ចសហប្រតិបត្តិការជាមួយ WWF**

ការសហប្រតិបត្តិការរវាង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាមួយអង្គការ WWF។ នៅឆ្នាំ២០២៤ ***វ.ស.ក.ក*** បានសហការក្នុងការរៀបចំចម្ការបង្ហាញអំពីបច្ចេកទេសដាំដុះនិងថែទាំចម្ការកៅស៊ូមិនទាន់ផ្ដល់ផលនិងបច្ចេកទេសប្រមូលផលកៅស៊ូ នៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី និងសហការក្នុងបណ្ដុះបណ្ដាលបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នឹងបានរៀបចំចម្ការបង្ហាញពង្រឹងសមត្ថភាពជនបង្គោលស្ដីពីបច្ចេកកៅស៊ូនៅក្នុងសហគមន៍កៅស៊ូគ្រួសារស្រុកកែវសីមា។

**៥.៣.៥ ការបោះពុម្ពនិងផ្សព្វផ្សាយៈ** វិទ្យាស្ថានបានបោះពុម្ពរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំស្ដីពីការងារស្រាវជ្រាវនិងផលិតកម្មដំណាំកៅស៊ូ។ ឯកសារបច្ចេកទេសកៅស៊ូ និងឯកសារការណែនាំអំពីជំងឺកៅស៊ូផ្សេងៗទៀតសរុបទាំងអស់មានចំនួន ១៦ប្រភេទ ស្មើនឹង១៦០០០ច្បាប់។

**៥.៣.៦ គេហទំព័រវិទ្យាស្ថាន(Website)៖** ក្នុងរយៈពេលមួយឆ្នាំ២០២៤ នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកៅស៊ូតាមរយៈគេហទំព័រ https://crri.com.kh របស់វិទ្យាស្ថានសរុបចំនួន 39 221 នាក់។

ដើម្បីធានាដល់ភាពជោគជ័យ លើសកម្មភាពនៃការអនុវត្តគម្រោងដោយផ្ទៀងផ្ទាត់លទ្ធផលដែលសម្រេចបានជាមួយនឹងសូចនាករ ដែលបានកំណត់នៅក្នុងផែនការ ការពិនិត្យ តាមដាន និងវាយតម្លៃគឺនឹងត្រូវធ្វើឡើង។ ការវាយតម្លៃនៃការអនុវត្តនេះត្រូវបានធ្វើឡើងនៅពេលកំពុងអនុវត្តរហូតដល់ការបញ្ចប់នៃគម្រោង ដោយនាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរបាយការណ៍ប្រចាំខែ របាយការណ៍ត្រីមាស របាយការណ៍ឆមាស របាយការណ៍ប្រចាំឆ្នាំ និងការចុះវាយតម្លៃដោយផ្ទាល់រៀងរាល់ឆ្នាំ។ ***វ.ស.ក.ក*** ក៏មានការរៀបចំជាគណៈកម្មការវាយតម្លៃផ្ទៃក្នុងផ្ទាល់ខ្លួនផងដែរ សម្រាប់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធានាបាននូវភាពច្បាស់លាស់ ហើយនិងភាពជោគជ័យនៃការអនុវត្តគម្រោង។

## ៦.សេចក្តីសន្និដ្ឋាន និងសំណូមពរ

ការងារអនុវត្តសម្រេចបាន១០០% ធៀបទៅនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការថវិកាតាមកម្មវិធី មិនតែប៉ុណ្ណោះសកម្មភាពស្រាវជ្រាវជាច្រើនទៀត ត្រូវបានអនុវត្តក្រៅពីផែនការដែលបានកំណត់នៅក្នុងកម្មវិធី។ លទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងមន្ត្រីរាជការ និយោជិតទាំងអស់ ជាមួយថ្នាក់ដឹកនាំ ***វ.ស.ក.ក*** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវ ក្នុងបេសកកម្មរបស់ខ្លួននិងផែនការ ដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះ ក៏មានការយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័ន ជំនាញជាអណាព្យាបាលរួមមាន៖ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*** ។ សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានដោយមានការចូលរួមពីបណ្តាដៃគូជាតិ រួមមានប្រតិបត្តិករកៅស៊ូទាំងអស់ដែលបានផ្តល់ការទុកចិត្ត ចូលរួមនិងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួមសហការពីបណ្តាដៃគូអន្តរជាតិពាក់ព័ន្ធដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS, WWF,...។

ក្នុងបរិបទទីផ្សារសេរី ការលើកស្ទួយភាពប្រកួតប្រជែង និងសមាហរណកម្មក្នុងតំបន់ ហើយក៏ដូចទៅនឹងកង្វះខាត កម្លាំងពលកម្មក្នុងវិស័យកសិកម្មផងដែរនោះ និងថ្វីត្បិតតែកន្លងមក វិទ្យាស្ថានសម្រេចបាននូវលទ្ធផលយ៉ាងគាប់ប្រសើរ ប៉ុន្តែវិទ្យាស្ថានបាននិងកំពុងតែជួបប្រទះនូវ (១)កង្វះមន្ត្រីជំនាញតាមផ្នែកនីមួយៗ ដែលទន្ទឹមនឹងគ្នានោះ មន្ត្រីជំនាញមួយចំនួនកាន់តែចាស់ (២)មធ្យោបាយសម្រាប់បំពេញបេសកម្ម ការចុះធ្វើពិសោធន៍ និងតាមដាននៅតាមខេត្តមានសភាពកាន់តែទ្រុឌទ្រោម និងមិនគ្រប់គ្រាន់ឆ្លើយតបទៅនឹងវឌ្ឍនភាពនៃការពិសោធន៍ (៣)កង្វះមន្ទីរពិសោធនិងសម្ភារៈដែលជួយគាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវ (៤)មិនមានការលើកទឹកចិត្តណាមួយដល់អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងអ្នកបម្រើការងារគាំទ្ររបស់វិទ្យាស្ថាន (៥)កង្វះកំលាំងពលកម្មក្នុងការថែទាំ និងចៀរជ័រកៅស៊ូ។ ដូច្នេះដើម្បីលើកស្ទួយវិស័យស្រាវជ្រាវដែលរាជរដ្ឋាភិបាលចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ វិទ្យាស្ថានសំណូមពរដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអាណាព្យាបាល មេត្តាពិនិត្យលទ្ធភាពដោះស្រាយ ឬកាត់បន្ថយ នូវបញ្ហាទាំង ៥ខាងលើ។

## ៧.ទិសដៅការងារសម្រាប់ឆ្នាំ២០២៥

ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០២៥នេះ វិទ្យាស្ថាននឹងបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយអង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានា ដៃគូអភិវឌ្ឍន៍ វិស័យឯកជនពាក់ពន្ធ ក៏ដូចជា កសិករ ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវតាមចង្កោមសកម្មភាពចម្បងចំនួនបីរបស់ខ្លួនគឺ៖

**ចង្កោមសកម្មភាពទី១.៦.១៖** ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ៖ ក្នុងគោលបំណងធ្វើការពង្រឹងដល់មូលដ្ឋានបច្ចេកទេសមន្ទីរពិសោធន៍ បច្ចេកទេសរោងចក្រកែច្នៃកៅស៊ូ ការចុះបញ្ជិការរោងចក្រ និងការទទួលស្គាល់ពីមន្ទីរពិសោធមូលដ្ឋាន និងសិទ្ធប្រើប្រាស់ស្លាកសញ្ញា CSR និងការស្រាវជ្រាវ ការអភិវឌ្ឍបច្ចេកទេសកែច្នៃក្នុងនោះវិទ្យាស្ថាននៅតែបន្តការងារដូចជា (១)តេស្តអន្តរមន្ទីរពិសោធន៍ (២)ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងគុណភាពកៅស៊ូអន្តរជាតិ (៣)ការធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូ (បង្កើនចំនួនសំណាកនៃការធ្វើតេស្តទៅលើកៅស៊ូសន្លឹ (RSS) និងកៅស៊ូដុំ(TSR))។

**ចង្កោមសកម្មភាពទី១.៦.២៖** ពង្រឹងការពិសោធន៍និងការស្រាវជ្រាវដំណាំកៅស៊ូ៖ ក្នុងគោលបំណងរៀបចំបង្កើតការគ្រប់គ្រងនិងស្រង់ទិន្នន័យចម្ការពិសោធន៍ ការបង្កាត់ ធ្វើជម្រើស អភិវឌ្ឍក្លូនកៅស៊ូ គ្រប់គ្រងច្បារពូជ អភិវឌ្ឍរុក្ខសម្ភារកៅស៊ូ វិភាគសរីរៈទឹកជ័រ ធ្វើការផ្លាស់ប្តូរក្លូនកៅស៊ូជាមួយបណ្តាសមាជិក IRRDB ក្នុងការអភិវឌ្ឍក្លូន និងធនធានសេនេទិចកៅស៊ូ និងធ្វើពិពិធកម្មប្រភេទដំណាំចន្លោះរង ដោយយកដំណាំកៅស៊ូជាមូលដ្ឋាន។ វិទ្យាស្ថាននៅតែបន្តការងារនិងការស្រាវជ្រាវរបស់ខ្លួន ព្រមទាំងខិតខំបន្ថែមទៅលើ (១)ផ្នែកស្រាវជ្រាវអំពីការបង្កាត់ពូជ នឹងពង្រីកទំហំនិងចំនួននៃការថែទាំច្បារពូជ និងច្បារបង្កាត់ពូជកៅស៊ូ ព្រមទាំងបង្កើនចំនួនសំណាក់នៃការប្រមូលសំណាក់ទឹកជ័រក្នុងចម្ការពិសោធន៍ក្លូនដើម្បីវិភាគសរីរសាស្ត្រទឹកជ័រ (LD) និងបង្កើនចំនួនដង នៃការចុះអង្កេតស្ថានភាពជំងឺកៅស៊ូនៅតាមបណ្តាខេត្តផ្សេងៗទៀត។ (២)ផ្នែកសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រ នឹងបន្តអភិវឌ្ឍ អភិរក្ស និងគ្រប់គ្រងក្លូនកៅស៊ូបន្ថែម បន្តការពិសោធន៍លើការលាបថ្នាំរំញោចនិងវិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រ ព្រមទាំងបង្កើនចំនួនចម្ការពិសោធន៍និងសំណាក់ដើម្បីវិភាគសរីរទឹកជ័រ (LD)។ (៣)ការងារដាំដុះនិងការពារ នឹងបន្តការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ ដំណាំគម្របដី ផលិតកម្មជីវម៉ាស់និងវិធានការគ្រប់គ្រងដំណាំគម្របដី ព្រមទាំងទំនាក់ទំនងរវាងការលូតលាស់ និងទិន្នផល ទៅនឹងអាកាសធាតុ ហើយនិងចង្វាក់ចៀរជ័រ។

**ចង្កោមសកម្មភាពទី១.៦.៣៖** សកម្មភាពគាំទ្រដំណើរការរដ្ឋបាលក្នុងគោលបំណងកសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីជុំរុញការងារពិសោធន៍និងស្រាវជ្រាវ និងការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ចង្កោមសកម្មភាពនេះ វិទ្យាស្ថានមានផែនការបណ្តុះបណ្តាលអ្នកជំនាញឲ្យបានយ៉ាងតិច០២នាក់ បង្កើនចំនួននៃការបោះពុម្ពអត្ថបទនិងសៀវភៅស្រាវជ្រាវវិទ្យាសាស្ត្រ ពង្រឹងភាពជាដៃគូស្រាវជ្រាវជាមួយបណ្តាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិមួយចំនួន ព្រមទាំងបន្តការយកចិត្តទុកដាក់លើការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ។ នៅឆ្នាំ២០២៥នេះផងដែរវិទ្យាស្ថាននឹងសាងសង់ផ្ទះកម្មករចំនួន២៥ខ្នង សាងសង់ផ្លូវកៅស៊ូក្នុងស្ថានីយ៍ប្រវែង៥០០ម៉ែត្រទំហំ៦ម៉ែត្រ និងរបងស្ថានីយ៍ប្រវែង៥០០ម៉ែត្រផងដែរ។

## ១. ព្រឹត្តិការណ៍សំខាន់ៗដែលថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានបានចូលរួមក្នុងឆ្នាំ២០២៤

ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រគល់ពានរង្វាន់ចំណាត់ថ្នាក់លេខ១ ក្នុងកម្មវិធីប្រកួតចៀរជ័រកៅស៊ូថ្នាក់ជាតិប្រចាំឆ្នាំ២០២៤ នៅចម្ការកៅស៊ូជុប ស្ថិតនៅឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដល់លោក ថា វាសនា និង លោក អុល ប៊ុនថន កម្មករចៀរជ័រនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។






ឯកឧត្តម **ប្រាក់ ដាវីដ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញចុះពិនិត្យច្បារពូជក្លូនកៅស៊ូកម្ពុជា CRRI 12 និង CRRI 19 របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្នុងទស្សនកិច្ចក៏មានការចូលរួមផងដែរ ពីសំណាក់លោកជំទាវ **អ៊ឹម រចនា** អនុរដ្ឋលេខាធិការ លោក **ឃុន ភក្ដដា** អគ្គនាយកស្ដីទីនៃអគ្គនាយកដ្ឋានកៅស៊ូនិងសហការី លោក **ផេន តារុន** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី។




## ១. ព្រឹត្តិការណ៍សំខាន់ៗដែលថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានបានចូលរួមក្នុងឆ្នាំ២០២៤

លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានអមដំណើរ **ឯកឧត្តម ចាន់ សារុទ្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចុះពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវនៅស្ថានីយពិសោធន៍ វ.ស.ក.ក





លោកជំទាវ **អ៊ឹម រចនា** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ចុះរៀបចំថតវីដេអូផ្សព្វផ្សាយអំពីការអភិវឌ្ឍអនុវិស័យកៅស៊ូ





ឯកឧត្តម **គី ច័ន្ទរំដួល** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវនៅស្ថានីយពិសោធន៍ វ.ស.ក.ក





លោក **លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានទទួលដំណើរ
ទស្សនកិច្ចរបស់គណៈប្រតិភូ AFD, CIRAD និង GDA នៅស្ថានីយពិសោធន៍នៃ វ.ស.ក.ក.









នៅព្រឹកថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ លោក **លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានអញ្ជើញចូលរួមពិធី “រុក្ខទិវា” នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើបន្ទាយអង្គរ ភូមិខ្នា ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ស្ថិតក្រោមព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។





ថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ លោក **លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ AFD, CIRAD, GDR , FORSEA project នៅស្ថានីយពិសោធន៍នៃ វ.ស.ក.ក. ។

















ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំនិងមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គនាយកដ្ឋានកៅស៊ូ បានរៀបចំកម្មវិធីប្រឡងចៀរជ័រសាកល្បងនៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃការអនុវត្តការចៀរជ័រឲ្យមានប្រសិទ្ធភាពខ្ពស់ និងរក្សាគុណភាពដើមកៅស៊ូ ព្រមទាំងជាការលើកទឹកចិត្ត និងការទាក់ទាញកម្លាំងពលកម្មសម្រាប់បម្រើកាងារក្នុងអនុវិស័យនេះផងដែរ។ កម្មវិធីនេះមានការចូលរួមពីកម្មករប្រឡងចៀរជ័រសាកល្បងចំនួន៣០នាក់។









## ២. យន្តការតម្រង់ទិសរបស់វិទ្យាស្ថាន

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លើកទី១អាណត្តិឆ្នាំ២០២៣-២០២៦ ដោយមានការអញ្ជើញចូលរួមជាអធិបតីពី ឯកឧត្តម **ចាន់ សារុទ្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសមាជិកក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន។







ថ្ងៃអង្គារ ១២រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្រោមអធិបតីភាពលោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃការអនុវត្តការងារក្នុងខែមករា និងលើកទិសដៅសម្រាប់អនុវត្តក្នុងខែកុម្ភៈ ឆ្នាំ២០២៤។




## ៣. កិច្ចប្រជុំជាមួយដៃគូរជាតិ និងអន្តរជាតិ

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤នេះ ឯកឧត្តម **តូច ប៊ុនហួរ** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការបញ្ចេញពូជដំណាំ បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមការងារពាក់ព័ន្ធដំណាំកៅស៊ូ ដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំបញ្ចេញប្រភេទក្លូនកៅស៊ូចំនួន ២ប្រភេទ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។









## ៨. ការថែទាំច្បារពូជ និងច្បារបង្កាត់ពូជ



សកម្មភាពតាមដានការជ្រុះស្លឹកច្បារបង្កាត់ពូជ



សកម្មភាពថែទាំច្បារពូជកៅស៊ូ



ច្បារពូជកៅស៊ូក្លូនកៅស៊ូកម្ពុជា CRRI 19



សកម្មភាពស្រង់ទិន្នន័យជំងឺប្រផេះស (*Oidium*)



សកម្មភាពចុះត្រួតពិនិត្យច្បារពូជកៅស៊ូគ្រួសារ




ឯកឧត្តម **ចាន់ សារុន្ធ** ចុះពិនិត្យច្បារពូជកៅស៊ូគ្រួសារ

## ៩. ការថែទាំថ្នាល់បណ្ដុះកូនកៅស៊ូ



សកម្មភាពថ្នាលបណ្តុះកូនកៅស៊ូ



សកម្មភាពដាក់គ្រាប់កៅស៊ូនៅថ្នាលបណ្តុះកូន



ការបំបៅកូនកៅស៊ូនៅថ្នាលកូនឆ្នាំ២០២៤



សកម្មភាពរៀបចំកូនកៅស៊ូផ័ត្រ



សកម្មភាពដាក់ជីបំប៉នកូនកៅស៊ូផ័ត្រ



សកម្មភាពបាញ់ថ្នាំការពារនិងព្យាបាលជំងឺស្លឹក

## ៦. ការដាំដុះ និងថែទាំកូនកៅស៊ូ



សកម្មភាពភ្ជួររាស់រៀបចំដី



សកម្មភាពបោះបង្គោលតម្រុយ



សកម្មភាពខួងរណ្ដៅ



សកម្មភាពដាក់ជីលាមកគោត្រាប់បាត



សកម្មភាពដាំដុះកូនកៅស៊ូឆ័ត្រ



សកម្មភាពជំរះស្មៅរែករងកៅស៊ូ

## ៧. ការងារក្នុងចម្ការពិសោធន៍



សកម្មភាពដាក់ជីចម្ការពិសោធន៍កៅស៊ូផ្តល់ផល



សកម្មភាពដាក់ជីចម្ការពិសោធន៍កៅស៊ូផ្តល់ផល



សកម្មភាពវាស់ទំហំដើមឈើព្រៃនៅចន្លោះរងកៅស៊ូ



សកម្មភាពវាស់ទំហំដើមកៅស៊ូចម្ការពិសោធន៍



សកម្មភាពតាមដានទិន្នផលជ័រកៅស៊ូចម្ការពិសោធន៍



សកម្មភាពបញ្ចូលទិន្នន័យចម្ការពិសោធន៍

## ៨. ការពិសោធន៍នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ



សកម្មភាពនៃការធ្វើតេស្ត$P_0$ និងPRI



សកម្មភាពធ្វើការធ្វើតេស្តវីស្កូស៊ីធីមូនី



សកម្មភាពនៃការធ្វើតេស្តរកបរិមាណផេះ



សកម្មភាពនៃការធ្វើតេស្តរកបរិមាណអាសូត



សកម្មភាពនៃការធ្វើតេស្តរកសារធាតុហើរ



សកម្មភាពនៃការធ្វើតេស្តរកអសុទ្ធភាព

## ការចុះពិនិត្យតាមដាន និងពង្រឹងគុណភាពក្នុងការកែច្នៃកៅស៊ូរបស់រោងចក្រយថាប្រភេទកៅស៊ូ TSR នៃក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន អាហ្គ្រោអ៊ិនដាសស្ទ្រៀល ផ្លេន



សកម្មភាពពិនិត្យបរិស្ថានក្នុងបរិវេនរោងចក្រ



ការពិនិត្យខ្សែសង្វាក់ផលិតកម្មកែច្នៃជ័រទឹក



សកម្មភាពត្រួតពិនិត្យខ្សែសង្វាក់ឧបករណ៍លោហៈក្នុងដុំជ័រ



ការត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្មកែច្នៃជ័រកក



សកម្មភាពកាត់យកសំណាកដើម្បីពិនិត្យគុណភាព



កិច្ចពិភាក្សាអំពីការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ

សកម្មភាពចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ CSR នៃក្រុមហ៊ុន បាវ មេន អ៊ិនដាសស្ទ្រី ឯ.ក









សកម្មភាពចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ CSR ក្រុមហ៊ុនសុភក្តនីកា អ៊ិនវេសមេន គ្រុប ខូ,. អិលធីឌី









សកម្មភាពចុះត្រួតពិនិត្យវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋាននៃក្រុមហ៊ុន បាវ មេន អ៊ិនដាសស្ទ្រី ឯ.ក









សកម្មភាពចុះត្រួតពិនិត្យមន្ទីរពិសោធន៍មូលដ្ឋានក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ









## ៩. ការពិសោធន៍សរីរសាស្ត្រទឹកជ័រ




សកម្មភាពយកសំណាកទឹកជ័រដើម្បីវិភាគសរីរទឹកជ័រ



ក្រុមការងារយកសំណាកទឹកជ័រ



ដំណើរការវិភាគសរីរសាស្ត្រទឹកជ័រ




សកម្មភាពវិភាគសរីរសាស្ត្រទឹកជ័រ

## ១០. ការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារក្រោមកិច្ចសហការជាមួយអង្គការ WWF














## ១១. ការចុះទស្សនកិច្ចនៅស្ថានីយអនុវត្តនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា





ការចុះទស្សនកិច្ចរបស់និស្សិតវិទ្យាស្ថានជាតិកសិកម្មកំពង់ចាមនៅស្ថានីយពិសោធន៍









ជំនាញការ CIRAD ចុះសិក្សាស្តីពីការព្យាករណ៍ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុរបស់គំរោង FORSEA នៅស្ថានីយពិសោធន៍នៃ CRRI



វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានសហការជាមួយអង្គការស្រាវជ្រាវកសិកម្មនិងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសបារាំង (CIRAD) បានរៀបចំសិក្ខាសាលាស្តីពីកសិរុក្ខកម្មកៅស៊ូ នៅស្ថានីយពិសោធន៍នៃ CRRI



គណៈប្រតិភូ CATAS ចុះសិក្សាស្វែងយល់អំពីការងារស្រាវជ្រាវនៅស្ថានីយពិសោធន៍នៃ CRRI

# ១២. ឯកសារបោះពុម្ពផ្សព្វផ្សាយ



ក្លូន RRIC 121



ក្លូន RRIM 712



ក្លូន RRIM 600

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/០១

## អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជា សម្រាប់ឆ្នាំ២០២៣ - ២០២៥



*ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*
*ការិយាល័យបង្កាត់ពូជ*

## អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជា សម្រាប់ឆ្នាំ ២០២៣ - ២០២៥

### ១. អនុសាសន៍ក្លូនសម្រាប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

**ថ្នាក់១៖** ជាបណ្ដាក្លូនដែលមានទិន្នផលខ្ពស់ និងមានលក្ខណៈក្សេត្រសាស្ត្រល្អ ដោយបានដាំសាកល្បងនៅក្នុងចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ ហើយត្រូវបានសិក្សាលើទិន្នន័យផ្សេងៗ រួមទាំងការប្រមូលផលរយៈពេលយ៉ាងតិច៧ឆ្នាំ។ ក្លូនទាំងនេះជារួមមានពី៣ទៅ៥ក្លូន ដែលគេគប្បីដាំនៅលើផ្ទៃដីពី៥០ទៅ៥៥%នៃផ្ទៃដីគ្រោងដាំកូនកៅស៊ូប្រចាំឆ្នាំ ដោយដាំក្លូននីមួយៗ ពី១៥ទៅ២០%។

**ថ្នាក់២៖** ជាបណ្ដាក្លូនដែលមានទិន្នផលខ្ពស់មានលក្ខណៈក្សេត្រសាស្ត្រល្អ (ចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ) ប៉ុន្តែមានទិន្នន័យតិចតួច។ គេគប្បីដាំក្លូនទាំងនេះនៅលើផ្ទៃដី ៤០% នៃផ្ទៃដីគ្រោងដាំកូនកៅស៊ូប្រចាំឆ្នាំ ដោយដាំក្លូននីមួយៗប្រមាណ១០%។

**ថ្នាក់៣៖** រាប់បញ្ចូលនូវក្លូនទាំងឡាយដែលគេបានដាំជាលក្ខណៈពិសោធន៍ទ្រង់ទ្រាយតូច ហើយគេសង្កេតឃើញថាក្លូននោះផ្ដល់ទិន្នផលខ្ពស់ មានលក្ខណៈក្សេត្រសាស្ត្រល្អ ប៉ុន្តែគេនៅមិនទាន់មានទិន្នន័យគ្រប់គ្រាន់នៅឡើយ ហើយគេគប្បីដាំបណ្ដាក្លូនទាំងនោះឱ្យបានច្រើនជាលក្ខណៈពិពិធកម្មនៅក្នុងចម្ការ។ ក្លូនទាំងនេះគប្បីដាំនៅលើផ្ទៃដីពី១ទៅ៥% នៃផ្ទៃដីគ្រោងដាំប្រចាំឆ្នាំ ឬដាំវាជាម៉ូណូក្លូន (ក្លូនតែមួយ) នៅលើផ្ទៃដីប្រមាណពី ៥ ទៅ ១០ហិកតា។

| ថ្នាក់១ | ថ្នាក់២ | ថ្នាក់៣ |
|---|---|---|
| RRIM 600 | GT 1 | IRCA 41 |
| RRIM 712 | IRCA 230 | IRCA 109 |
| IRCA 130 | KV 4 | IRCA 317 |
| PB 217 | PB 235 | IRCA 331 |
| PB 280 | PB 314 | PB 310 |
| | PB 254 | PB 324 |
| | PR 303 | PB 330 |
| | RRIC 100 | PR 255 |
| | RRIC 101 | PR 300 |
| | RRIC 121 | PR 306 |

### ២. អនុសាសន៍ក្លូនសម្រាប់ចម្ការកៅស៊ូគ្រួសារ

| ក្លូន | ទិន្នផល | ការលូតលាស់ | ភាពធន់នឹងខ្យល់ | ភាពធន់នឹងបម្រែបម្រួលបរិយាកាស |
|---|---|---|---|---|
| RRIM 600 | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| RRIM 712 | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម |
| PB 280 | ខ្ពស់ | ខ្ពស់ | មធ្យម | បង្គួរ |
| RRIC 100 | បង្គួរ | ខ្ពស់ | ខ្ពស់ | មធ្យម |

ដោយសមាសភាពក្លូននៅក្នុងបញ្ជីអនុសាសន៍ត្រូវបានផ្លាស់ប្ដូរពី៣ទៅ៥ឆ្នាំម្ដងគេគប្បីផ្ទៀងផ្ទាត់ឱ្យបានទៀងទាត់ថាតើច្បារពូជមាននូវក្លូនថ្មីៗដូចក្នុងបញ្ជីអនុសាសន៍ក្លូនដែរឬទេ?



ក្លូន PB 217



ក្លូន PB 280



ជំងឺ *Oidium* ធ្វើឱ្យការលូតលាស់របស់រុក្ខជាតិមានភាពយឺតយ៉ាវ ហើយការដុះសំបកថ្មីក៏យឺតផងដែរ។ នៅតំបន់មានរយៈកម្ពស់ខ្ពស់ការជ្រុះស្លឹកញឹកញាប់នាំមកនូវកង្វះអាហារបម្រុងទុកក្នុងដើម អាចបង្កឱ្យមានជំងឺ Dieback នៃមែកតូចធំដែលនាំឱ្យមានបរាសិតទីពីរកើតឡើងគឺ Bothryodiploidia theobromae Pat.។ *Oidium* hevea ធ្វើឱ្យផ្កាក្លាយជាពណ៌សហើយជ្រុះមុនពេញវ័យ ដែលបណ្តាលឱ្យផលិតកម្មគ្រាប់ថយចុះ។

### ៣. ការពារនិងព្យាបាល

- បំប៉នដីអាសូតនិងប៉ូតាសនៅពេលកៅស៊ូរៀបនឹងចេញស្លឹកថ្មី
- ដាំកូនធន់នឹងជំងឺដូចជា PR255, RRIC100, PB217,...
- ព្យាបាលដោយម្សៅស្ពាន់ធ័រ៦-៩គីឡូក្រាមក្នុងមួយហិកតា
- ទ្រីដេម័រ (Tridemorth) កម្រិត 0.02-0.04%
- ស៊ូឡុក (Sulox 1%) កម្រិត ៤-៥គីឡូក្រាមក្នុងមួយហិកតា
- នៅថ្នាលកូនប្រើឌីតាន (Dithane M45) កម្រិត ១% ចំនួន២គីឡូក្រាមក្នុងមួយហិកតា
- កាបិនដាស៊ីម (Carbendazim) កម្រិត 0.05%។



**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០១៤/០២

# ជំងឺស្លឹកអូអ៊ីដ្យូមឬប្រផេះស
## *Oidium* Leaf disease



*ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*
*ការិយាល័យដាំដុះនិងការពារ*

### ១. លក្ខណៈទូទៅ

ជំងឺស្លឹកអូអ៊ីដ្យូមឬប្រផេះស (*Oidium* leaf disease) អាចកើតមានក្នុងកម្រិតខុសៗគ្នានៅតំបន់ដាំកៅស៊ូ។ បញ្ហានេះបណ្តាលមកពីការជ្រុះស្លឹកយឺត ឬពន្យាពេលជ្រុះស្លឹករបស់កូនកៅស៊ូ។ ភាពធ្ងន់ធ្ងរនៃជំងឺប្រែប្រួលទៅតាមរដូវជ្រុះស្លឹក អាយុស្លឹក កូនដាយចម្លងជំងឺនិងលក្ខខណ្ឌអាកាសធាតុនៅពេលស្លឹកលាស់ឡើងវិញ។ កូនកៅស៊ូដែលជ្រុះស្លឹកមុនដូចជា PB86, PB235, AF261, PB330... អាចគេចផុតពីជំងឺស្លឹកអូអ៊ីដ្យូម ឬ ប្រផេះស។ ជំងឺនេះរីករាលដាលដោយសារស្ព័រហើរតាមខ្យល់នឹងបង្កបញ្ហាខ្លាំងនៅតំបន់ខ្ពស់និងមានតិចតួចនៅតំបន់មានរយៈកំពស់ទាបជាង៩០ម៉ែត្រ។

### ២. រោគសញ្ញាជំងឺ

ជំងឺ *Oidium* leaf disease បង្កឡើងដោយផ្សិត *Oidium hevea* Stein។ ផ្សិតនេះបង្កើតស្ព័រមានលក្ខណៈជាម្សៅដែលមានមុខងារដូចប៉ាក់ស៊ីត (បញ្ញើក្អែក)។ កត្តាអាកាសធាតុមានសារសំខាន់ជាងគេដែលធ្វើឱ្យជំងឺវិវត្តទៅបាន។ កំដៅនិងសំណើមមានឥទ្ធិពលលើជីវិតរស់នៅ ការលូតលាស់ ការបំបែកស្ព័រ និងការចម្លងជំងឺនៃពពួកផ្សិត។ ពពួកផ្សិតរីកសាយភាយទៅគ្រប់ទិសទីដោយសារខ្យល់នាំទៅនូវពពួក Conidia ហើយការកកើតស្ព័រនិងការរាលដាលគឺទទួលឥទ្ធិពលពីអាកាសធាតុ ជាពិសេសសំណើមទាប កំដៅខ្ពស់ ជាទូទៅអាស្រ័យលើខ្យល់កួចខ្លាំងខណៈពេលដែលស្ព័រត្រូវរីកសាយភាយ។ ស្លឹកខ្ចីមានពណ៌ទង់ដែងនិងបៃតងក្រារ ជាតំណាក់កាលងាយទទួលរងជំងឺ។

រោគសញ្ញាលេចចេញជាស្នាមផ្ទាំងម្សៅពណ៌សលើផ្ទៃស្លឹកទាំងសងខាងនិងផ្ទៃក្រោមស្លឹកជិតទ្រនុង (Veins)។ ផ្សិតរាលដាលតភ្ជាប់ពីផ្ទាំងមួយទៅផ្ទាំងមួយទៀត ជួនកាលគ្របដណ្តប់លើផ្ទៃស្លឹកទាំងស្រុង។ នៅពេលស្លឹកខ្ចីកើតជំងឺវាក៏ស្វិត ហើយជ្រុះ បន្សល់តែទងស្លឹកជាប់ដើម។ នៅពេលស្លឹកកំពុងលូតលាស់ទទួលរងនូវជំងឺ នឹងបណ្តាលឱ្យផ្ទៃនិងទម្រង់ស្លឹកប្រែប្រួលខុសធម្មតា ហើយស្លាកស្នាមនៃជំងឺជិតជាប់លើផ្ទៃស្លឹកមានពណ៌លឿងក្រាបន្សល់ទុកលើស្លឹកពេញមួយវដ្តជីវិត។





ស្លឹកខ្ចីដែលរងនូវជំងឺបានបង្ហាញយ៉ាងច្បាស់នូវស្នាមម្សៅពណ៌សលើស្លឹក ហើយស្នាមនេះចាប់ផ្តើមប្រែពណ៌ទៅជាពណ៌ត្នោតនិងក្លាយជាដំបៅលួយ។ ការវាតត្បាតខ្លាំងរបស់ *Oidium* ធ្វើឱ្យស្លឹកជ្រុះច្រើន និងបុស្សុក (Canopies) មានសភាពអន់ថយ ហើយទិន្នផលធ្លាក់ចុះ។

បើសិនជំងឺកើតលើស្លឹកចាស់ចាប់ពី១០ថ្ងៃឡើង ស្លឹកមិនជ្រុះទេ ប៉ុន្តែវាបន្សល់ទុកនូវស្នាមខ្មៅខ្លូងនៅលើស្លឹក ធ្វើឱ្យស្លឹកបាក់ ហើយស្លឹកជ្រុះច្រើនជាបន្តបន្ទាប់រហូតដល់ងាប់ត្រួយនិងមែក។

នៅពេលស្លឹកមិនទាន់ចាស់ទទួលរងដោយផ្សិត តាមធម្មតាភាពធន់នៃបាហនិក (host) ការពារមិនឱ្យមានគ្រោះមហន្តរាយខ្លាំង គ្រាន់តែធ្វើឱ្យស្លឹកមានស្នាមអុចពណ៌ត្នោតជាច្រើន ព័ទ្ធជុំវិញដោយរង្វង់ពណ៌លឿង។ នៅពេលស្នាមអុចលេចចេញកាន់តែច្រើន ផ្សិតធ្វើឱ្យមែកឈើតូច ធំ ងាប់បន្តិចម្តងៗ ហើយងាប់ដល់ដើមទាំងស្រុងនៅពេលជំងឺកាន់តែខ្លាំងឡើង ជាពិសេសនៅតំបន់ខ្ពស់ឬតំបន់មានសំណើមខ្លាំង។





## ៤. ការពារនិងព្យាបាល

- បំប៉នដីនៅពេលកៅស៊ូរៀបនឹងចេញស្លឹកថ្មី
- ដាំកូនធន់នឹងជំងឺដូចជា PB217, RRIM600,...
- ឌីតាន (Dithane M45) កម្រិត 0.5-1% ចំនួន ២គីឡូក្រាមក្នុងមួយហិកតា
- កាបិនដាស៊ីម (Carbendazim) កម្រិត 0.2-0.3% ក្នុងមួយសប្តាហ៍ម្តង
- Maneb, Zineb កម្រិត 0.3-0.5% ៕


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/០៣


# ជំងឺស្លឹកកូឡេតូទ្រីកូមឬក្រៀមខ្មៅកន្ទុយស្លឹក
# *Colletotricum* Leaf disease




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ការិយាល័យដាំដុះនិងការពារ


## ១. លក្ខណៈទូទៅ

ជំងឺស្លឹកកូឡេតូទ្រីកូមឬក្រៀមខ្មៅកន្ទុយស្លឹក(*Colletotrichum leaf disease*) មានកើតនៅប្រទេសដាំកៅស៊ូជាច្រើនតាមកម្រិតធ្ងន់ ឬស្រាលខុសៗគ្នា។ ជំងឺនេះរាតត្បាតលើស្លឹកកូនកៅស៊ូនិងកើតលើស្លឹកលាស់ថ្មីនៃដើមកៅស៊ូពេញវ័យក្រោយពេលរដូវជ្រុះស្លឹក។ ជំងឺនេះកើតពេញមួយឆ្នាំ ហើយកើតខ្លាំងជាងគេនៅពេលចាប់ផ្តើមអាកាសធាតុសើមដែលធ្វើឱ្យស្លឹកជ្រុះច្រើនចំពោះកូនងាយទទួលរងជំងឺ។ ជំងឺមានសភាពធ្ងន់ធ្ងរនៅពេលស្លឹកជ្រុះលើកទីពីរគឺអាស្រ័យលើកូនងាយទទួលរងជំងឺដោយផ្សិតនិងលក្ខខណ្ឌអាកាសធាតុនៅពេលស្លឹកលាស់ជាថ្មីឡើងវិញ។





## ២. ការបង្កជំងឺ

ជំងឺ *Colletotrichum* បណ្តាលមកពីផ្សិត *Colletotrichum gloeosporioides* (peuz.) Saee។ សីតុណ្ហភាពដែលអំណោយផលដល់ការលូតលាស់និងរាតត្បាតនៃជំងឺក្នុងចន្លោះ ២៦-៣២°C និងអតិបរមា ២៨ °C ។ ដំណុះស្ព័រនឹងថយចុះភ្លាមៗខណៈគេដាក់នៅហាលក្តៅនិងកំដៅកាំរស្មីស្វាយអ៊ុលត្រាក្នុងរយៈពេលខ្លី។ កម្រិតសំណើម ៩៩% ជីវិតរស់នៅនិងការលូតលាស់របស់ស្ព័រ (spore) បានកាត់បន្ថយ ៥០% បើប្រៀបធៀបទៅនឹងសំណើម ១០០%។

*C. gloeosporioides* នៃ *Hevea* មានបម្រែបម្រួលយ៉ាងខ្លាំងក្នុងការលូតលាស់លក្ខណៈរូបសាស្ត្រ សមត្ថភាពនៃការបំបែកស្ព័រនិងការបាត់បង់សមត្ថភាពរាតត្បាតរបស់វា។ ប្រភេទរុក្ខជាតិច្រើនជាង១៥០ប្រភេទ ឈើផ្សេងៗទៀតក៏រងនូវជំងឺផ្សិតនេះផងដែរ ដូចជា ស្វាយ កាហ្វេជាដើម...។

## ៣. រោគសញ្ញាជំងឺ

សញ្ញាជំងឺច្រើនកើតលើស្លឹកខ្ចីដែលមានអាយុក្រោម១០ថ្ងៃ។ ជំងឺចាប់ផ្តើមដំបូងលើចុងស្លឹកបន្ទាប់មករាលដាលកាន់តែធំឡើងរហូតធ្វើឱ្យស្លឹកជ្រុះ។



## ៤. ការរាលដាលជំងឺ

នៅថ្នាលបណ្ដុះកូន (Nursery) កូនកៅស៊ូមិនទាន់បំប៉ោងាយរងនូវជំងឺៗ ចំណែកនៅច្បារពូជនិងចម្ការកៅស៊ូ ជំងឺរាតត្បាតភាគច្រើនលើកូនៈ RRIC52, RRIC103, RRIC104, RRIC110, RRIM725, RRIC106, PR107, PR255, PB235, PB260, PB311, PB86, PB255, RRII300, RRII305,…

ចំពោះកូនដែលធន់នឹងជំងឺមានៈ RRIC100, RRIC102, RRIM600, PB217,...

## ៥. ការការពារនិងព្យាបាលថ្នាលបណ្ដុះកូន

ដើម្បីទប់ស្កាត់ជំងឺនេះ នៅថ្នាលបណ្ដុះកូន (Nursery) គេមិនគួរប្រើដើងទម្រចេញពីគ្រាប់កៅស៊ូនៃបណ្ដាកូនងាយរងនូវជំងឺមានដូចជាៈ PR107, PR255, PB235, PB260, PB311, PB86,...



ការពារការកកើតជំងឺនៅថ្នាលបណ្ដុះកូនដោយការបាញ់ថ្នាំក្នុងរយៈពេល**៥ថ្ងៃម្ដង**នូវប្រភេទថ្នាំៈ
- ឌីតានអឹម៤៥ (Dithane M45) កម្រិត 0.3% (3g/1l ទឹក)
- កាប់តាន (Captan)កម្រិត 0.4% (4g/1l ទឹក)
- អង់ត្រាក់កុល (Antracol) កម្រិត 0.4% (4g/1l ទឹក)

### ច្បារពូជនិងចម្ការកៅស៊ូ

នៅច្បារពូជនិងចម្ការកៅស៊ូគេបាញ់ថ្នាំ១សប្ដាហ៍ម្ដងនូវប្រភេទថ្នាំៈ
- ឌីតានអឹម៤៥ (Dithane M45) កម្រិត 0.3% (3g/1l ទឹក)
- ម៉ង់កូសែប (Mancozeb) កម្រិត 0.3% (3g/1l ទឹក)
- កាប់តាន (Captan) កម្រិត 0.4% (4g/1l ទឹក)
- អង់ត្រាក់កុល (Antracol) កម្រិត 0.4% (4g/1l ទឹក)
- ហ្ស៊ីនែប (Zineb) កម្រិត 0.2-0.75%
- ប្រូពីនែប (Propineb) កម្រិត 0.5% ។


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/០៤


# ជំងឺជ្រុះស្លឹកករីណេស្ប៉ូរ៉ា

## *Corynespora* Leaf fall disease




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ


## ១. លក្ខណៈទូទៅ

ក្នុងពេលបច្ចុប្បន្ន ជំងឺជ្រុះស្លឹកករីណេស្ប៉ូរ៉ា (*Corynespora* leaf fall) ត្រូវបានចាត់ទុកជាជំងឺបំផ្លាញដ៏ធំធេងមកលើដំណាំកៅស៊ូៗ ជំងឺនេះបានកើតឡើងនៅប្រទេស ឥណ្ឌា ម៉ាឡេស៊ី ថៃ ស្រីលង្កា ឥណ្ឌូនេស៊ី បង់ក្លាដេស វៀតណាម កាម៉ារូន នីហ្សេរីយ៉ានិងកូដឌីវ័រ ហើយថ្មីៗនេះក៏មានវត្តមាននៅកម្ពុជាផងដែរ។ នៅប្រទេសដាំកៅស៊ូជាច្រើន ជំងឺនេះបង្កមហន្តរាយខ្លាំងតែកូនមួយចំនួនប៉ុណ្ណោះ។ នៅស្រីលង្កាជំងឺនេះបានបង្កមហន្តរាយជាង៣០០០ ហិកតានៃកូនដែលងាយទទួលជំងឺ ជាពិសេសកូន RRIC103 ទាំងនៅក្នុងចម្ការកៅស៊ូថ្មីក៏ដូចក្នុងចម្ការកៅស៊ូចាស់ៗ រីឯនៅវៀតណាមជំងឺនេះវាយប្រហារធ្ងន់ធ្ងរលើកូន RRIV4 ។ ជំងឺនេះរាតត្បាតលើស្លឹកកៅស៊ូគ្រប់វ័យពេញមួយឆ្នាំៗ។

## ២. រោគសញ្ញាជំងឺ

ជំងឺជ្រុះស្លឹកករីណេស្ប៉ូរ៉ា បង្កឡើងដោយផ្សិត *Corynespora cassiicola* ។ ផ្សិតនេះមានឥទ្ធិពលទាំងនៅលើស្លឹកខ្ចីនិងស្លឹកចាស់ៗ នៅក្រោមលក្ខខណ្ឌអាកាសធាតុអំណោយផល ជំងឺនឹងរីករាលដាលបណ្ដាលឲ្យជ្រុះស្លឹកៗ

រោគសញ្ញាដំបូងនៅលើស្លឹកលេចឡើងនូវស្នាមពណ៌ត្នោតប្រផេះនិងមានស្នាមអុជច្រើនភ្ជាប់គ្នាជាផ្ទាំងដែលប្រមូលផ្ដុំផ្សិតរីកធំឡើងបង្កើតជាដំបៅ (lesions) ខ្មៅចជ្រួញនិងមានទ្រង់ទ្រាយមិនដូចគ្នា។



នៅលើស្លឹកចាស់លក្ខណៈពិសេសនៃជំងឺមានស្នាមពណ៌ត្នោត ឬក្រមៅលើទ្រនុងស្លឹកដែលមានសណ្ឋានដូច "**ឆ្អឹងត្រី**" (fishbone)។ ជាទូទៅស្លឹកកើតជំងឺបានប្ដូរពណ៌ពីបៃតងទៅជាលឿងដោយសារក្លរ៉ូហ្វីលត្រូវបានបំផ្លាញ ហើយចុងក្រោយស្លឹកប្រែពណ៌ក្រហមនិងជ្រុះៗ ការជ្រុះស្លឹកច្រើនដងអាចបណ្ដាលឲ្យកើតជំងឺ dieback នៅលើត្រួយនិងមែក ករណីធ្ងន់ធ្ងរធ្វើឱ្យងាប់ដើមទាំងស្រុងៗ

## ៣. លក្ខខណ្ឌកើតជំងឺ

ជំងឺរីករាលដាលដោយសារស្ព័រហើរតាមខ្យល់ៗ ក្នុង១សង់ទីម៉ែត្រការ៉េនៃស្លឹកកើតជំងឺមានស្ព័រប្រហែល១២០០ហើយស្ព័រទាំងនេះអាចមានជីវិតរស់នៅបានរយៈពេល១ខែទោះបីស្លឹកជ្រុះក៏ដោយ ដែលបង្ហាញថាផ្សិតអាចធន់នឹងលក្ខខណ្ឌមិនល្អ។ សីតុណ្ហភាពល្អបំផុតសម្រាប់ស្ព័រលូតលាស់គឺ៣០°C ប៉ុន្តែ ផ្សិតអាចកើតមាននៅសីតុណ្ហភាព១៥°C-៤០°C ផងដែរ។ ក្នុងករណីសំណើមខ្ពស់មានអំណោយផលដល់ការរីករាលដាលនៃជំងឺ ប៉ុន្តែបើសំណើមទាបជំងឺមិនរីករាលដាលខ្លាំងនោះទេ។



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/០៥

# ជំងឺផ្កាកុលាប
# Pink disease



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

## ១. លក្ខណៈទូទៅ

ជំងឺផ្កាកុលាប ជាជំងឺមួយដែលកើតនៅលើដើមនិងមែក ហើយមានឈ្មោះយោងទៅតាមពណ៌សម្បុរនៃរោគសញ្ញារបស់វា។ ជំងឺនេះរាលដាលពីសំបករួចចូលទៅក្នុងសាច់ឈើ។ វាចាប់ផ្ដើមរាតត្បាតភាគច្រើននៅត្រង់ប្រគាបមែក ព្រោះនៅកន្លែងនេះសំបកមានសំណើមជាប់យូរក្រស្ងួតក្រោយមេឃភ្លៀង។

## ២. ភ្នាក់ងារបង្កជំងឺ

ជំងឺនេះបណ្ដាលមកពីផ្សិត *Corticium salmonicolor* ។ ស្ព័ររបស់ផ្សិតនេះចម្លងពីដើមមួយទៅដើមមួយទៀតដោយសារខ្យល់។ ជំងឺចម្លងរាលដាលខ្លាំងនៅពេលអាកាសធាតុសើម នៅពេលផ្សិតបំភាយស្ព័រនិងផ្ទៃសំបកសើមល្មមធ្វើឱ្យស្ព័រលូតលាស់នឹងកកើតជាផ្សិតបាន។

វារាតត្បាតច្រើននៅពេលមានភ្លៀងធ្លាក់ជោគជាំ ពីខែកក្កដា, សីហា, កញ្ញា និងខែតុលា ហើយវាច្រើនកើតនៅលើដើមកៅស៊ូដែលមានអាយុពី ៣ ទៅ ១២ឆ្នាំ។



ជ័រហូរចេញនិងកកជាធ្លុតខ្មៅ

## ៣. ក្លូនងាយទទួលរងជំងឺ

ក្លូនដែលងាយរងជំងឺខ្លាំងមាន ក្លូន RRIM 600, PB314, PB 217 និង PB 311 រីឯក្លូនដែលធន់ជំងឺមានក្លូន PB 260, GT1 និង PR 107 ។



## ៤. សញ្ញាជំងឺ

នៅត្រង់កន្លែងបែកមែកមានសរសៃប្រទាក់គ្នា (ដូចសំបុកពីងពាង) ជាមួយនឹងការចេញជ័រជាពិសេសនៅកន្លែងប្រគាបមែក បន្ទាប់មករាលដាលរុំជុំវិញមែកនិងមានពណ៌ផ្កាកុលាប ប្រសិនបើមិនបានព្យាបាលទាន់ពេលវេលា សំបកក៏ស្ងួតប្រេះហូរជ័រចេញក្រៅ ហើយកកជាធ្លុតខ្មៅ។



ប្រគាបមែកមានពណ៌ផ្កាកុលាប

អាស្រ័យដោយការស្ទះនៃចលនាទឹកជ័រឡើងទៅផ្នែកខាងលើ បណ្ដាលឱ្យមានដុះចេញនូវមែកថ្មីនៅខាងក្រោមនៃផ្នែកដែលមានកើតជំងឺ ចំណែកឯមែកដែលកើតជំងឺ ជ្រុះស្លឹក បន្ទាប់មកក្រៀមងាប់។



មែកថ្មីដុះចេញនៅខាងក្រោមនៃផ្នែកកើតជំងឺ

## ៥. ការគ្រប់គ្រងជំងឺ

នៅពេលដែលពិនិត្យឃើញមានជំងឺនេះ គេត្រូវធ្វើការព្យាបាលភ្លាមៗ ជំងឺនេះបំផ្លាញមែកខ្ចីនិងផ្នែកនៃដើមនៅត្រង់កន្លែងបែកមែកនិងធ្វើឱ្យខូចសំបកយ៉ាងឆាប់រហ័សហើយនិងអាចបណ្ដាលឱ្យងាប់មែកនិងងាប់ចុងទាំងស្រុងទៀតផង។

ការព្យាបាលដោយជោគជ័យគឺអាស្រ័យលើការឆាប់ដឹងភ្លាមៗ ចាប់តាំងពីផ្សិតកកើតដំបូង។ កាលណាផ្សិតកើតរុំជុំវិញមែករួចហើយមែកនឹងងាប់ **គេមិនអាចព្យាបាលវាបានទេ។** ត្រូវព្យាបាលដោយបាញ់ថ្នាំសម្លាប់ផ្សិតលើមែកឈើ ដោយប្រើឧបករណ៍ដែលមានដងវែងនិងក្បាលបាញ់សាច។

ប្រសិនបើជំងឺធ្ងន់ធ្ងរ គឺត្រូវកាត់មែកដែលកើតជំងឺឱ្យដល់ផ្នែកខាងក្រោមដែលគ្មានជំងឺប្រវែង ៣០ស.ម រួចយកទៅកប់ ឬដុតចោល។ ដើម្បីគ្រប់គ្រងជំងឺនេះ គេអាចបាញ់ថ្នាំសម្លាប់ផ្សិតដូចជា៖

- ល្បាយប័រដូ (Bordeaux Mixture) លើមែក ចំពោះដើម



ការបាញ់ថ្នាំ Validamycin



ឧបករណ៍ព្យាបាលជំងឺផ្កាកុលាប

កៅស៊ូ**មិនទាន់ចៀរជ័រ** ដែលត្រូវបាញ់ប្រវែង៣០-៥០ស.មផ្នែកខាងលើនិងខាងក្រោមកន្លែងដែលកើតជំងឺ។ ថ្នាំនេះហាមប្រើចំពោះដើមកៅស៊ូកំពុងចៀរជ័រ ព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកជ័រ។

- ទ្រីដឺម័ហ្វ (Tridemorph) នៅកំហាប់ 1%
- វ៉ាលីដាមីស៊ីន (Validamycin) នៅកំហាប់ 1.5% - 2%។

ការបាញ់ប្រព្រឹត្តទៅពី១០-១៤ថ្ងៃម្ដង ហើយបាញ់ឱ្យបាន៣-៤ដងតាមភាពចាំបាច់ ចាប់ពីពេលកើតជំងឺ។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/០៦

# ជំងឺស្លឹកហ្វីតូផ្ទរ៉ាឬជ្រុះស្លឹករដូវភ្លៀង
## *Phytophthora* disease



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

### ១. លក្ខណៈទូទៅ

ជំងឺហ្វីតូផ្ទរ៉ា ឬ ជ្រុះស្លឹករដូវភ្លៀង (*Phytophthora palmivora* ឬ *P. botryosa*) អាចកើតនៅចម្ការកៅស៊ូរៀងរាល់ឆ្នាំនៅរដូវវស្សា ក្នុងខែឧសភា-កក្កដា។ ជំងឺនេះមានលក្ខណៈផ្ទុយគ្នាទៅនឹងជំងឺប្រផេះស(*Oidium*)។ ប្រសិនបើជំងឺប្រផេះសកើតមានច្រើននៅរដូវជ្រុះស្លឹកក្នុងខែមករា-មីនា នោះជំងឺជ្រុះស្លឹករដូវភ្លៀងកើតមានតិច ផ្ទុយទៅវិញបើស្លឹករងនូវជំងឺប្រផេះសកើតមានតិច នឹងបណ្តាលឱ្យជំងឺជ្រុះស្លឹករដូវភ្លៀង កើតមានច្រើន។ ជំងឺជ្រុះស្លឹករដូវភ្លៀង រីករាលដាលខ្លាំងដោយស្ព័រ (Spores) ដែលហូរនាំដោយទឹកភ្លៀង។

### ២. រោគសញ្ញាជំងឺ

#### ផ្លែ *(Pods)*

ដំបូងផ្លែមានដំបៅដែលមានរាងដូចជាតំណក់ទឹកទំហំប៉ុនក្បាលម្ជុល បន្ទាប់មករីវត្តន៍នៅផ្នែកខាងក្រោមពាក់កណ្តាលផ្លែ ពេលខ្លះមានតំណក់ជ័រកកជាប់នឹងផ្លែ។ បន្ទាប់ពី២-៣សប្តាហ៍ផ្លែមានកន្ទួលពណ៌សបង្កដោយស្ព័រ ហើយចម្លងមេរោគឱ្យស្លឹក



#### ស្លឹកជ្រុះ *(Leaf fall)*

រោគសញ្ញាកើតលើទងស្លឹក(*Petioles*) មានស្នាមដំបៅពណ៌ប្រផេះ ឬខ្មៅវិវត្តន៍លើទងស្លឹកនិងមានតំណក់ជ័រនៅលើដំបៅ ហើយពេលខ្លះស្លឹកទាំងមូលប្រែពណ៌ទៅជាលឿងនិងក្រហមមុននឹងជ្រុះ។



#### ងាប់ពន្លក,ត្រួយ *(Shoot die back)*

រោគសញ្ញាលេចឡើងនូវដំបៅពណ៌ប្រផេះ ឬខ្មៅនៅលើពន្លកដើមខ្ចី។ មេរោគរាលដាលយ៉ាងឆាប់រហ័សរហូតដល់ផ្នែកនៃដើមនិងបង្កឱ្យងាប់ដើម។



ពន្លកខ្ចីនៃទងស្លឹកកៅស៊ូកំពុងផ្តល់ផលរងនូវជំងឺនេះក៏អាចងាប់ដែរ។

#### ពុកសម្បក *(Back rot)*

ស្ព័រជ្រាបចូលតាមរយៈស្នាមរបួសដោយការចៀរជ័រ។ រោគសញ្ញាមានដំបៅពណ៌ប្រផេះ ឬខ្មៅនៅជិតមុខចៀរ នឹងលេចចេញរាងខ្វូងលើផ្ទាំងមុខចៀរ។ ផ្សិតរីករាលដាលនៅក្នុងជាលិកាសម្បកឈើ បន្ទាប់មកធ្វើឱ្យសម្បកប្រេះហើយជ័រជ្រាបចេញ។ នៅពេលសម្បកនិងសាច់ឈើឆ្លងមេរោគបានបង្ហាញលក្ខណៈឆ្នូតឈរពណ៌ខ្មៅដែលអាចមើលឃើញនៅលើសាច់ឈើ។

### ៣. ការការពារជំងឺ

១. ដាំកូនធន់នឹងជំងឺដូចជា៖ GT1, PB260, RRIM600, PB217, PB235...

២. ជំរះស្មៅនិងគ្របគល់ជុំវិញដើមកៅស៊ូ

៣. កាត់មែកខ្លះដើម្បីបង្កើនចរន្តខ្យល់និងធ្វើឱ្យចម្ការស្រឡះល្អ

៤. មិនត្រូវបើកមុខចៀរជ័រ ឬប្តូរមុខចៀរលើសម្បកកំណើតក្នុងរដូវវស្សា

៥. សម្លាប់មេរោគលើផ្ទាំងមុខចៀរ

៦. ការពារសម្បកកំណើតពីការឆ្លងមេរោគ ដោយប្រើថ្នាំសម្លាប់ផ្សិត Ridomil ក្នុងកម្រិត 5g/l ទឹក បន្ទាប់ពីប្រមូលទឹកជ័រនៅរាល់ថ្ងៃចៀរ ឬប្រើម្សៅ Sandofan ១សប្តាហ៍ម្តងនៅខែឧសភា-កញ្ញា។

### ៤. ការព្យាបាល

#### កូនកៅស៊ូ

កូនកៅស៊ូងាយរងនូវជំងឺ ដូច្នេះការព្យាបាលបន្ទាន់ជារឿងចាំបាច់។ ថ្នាំកម្ចាត់ផ្សិតត្រូវបានប្រើសម្រាប់ជំងឺយ៉ាងតិច១សប្តាហ៍ម្តងនៅរដូវវស្សា។

ថ្នាំប្រើលើកូនកៅស៊ូមានដូចជា៖

- កូពើសាន់ដូស Copper Sandoz (Baur & Co.) កម្រិត 3g/1l ទឹក
- ប៉េរេនុក Perenox (C.I.C.) កម្រិត 3g/1l ទឹក
- ហាក្រូសកូពើអុកស៊ីក្លរីត (Harcross Copper Oxychloride) កម្រិត 3g/1l ទឹក





- ឌីតានអឹម៤៥ (Dithane M45) កម្រិត 3g/1l ទឹក
- ម៉ង់កូសែប (Mancozeb) កម្រិត 3g/1l ទឹក
- មេតាលាក់ស៊ីល (Metalaxyl Mz) កម្រិត 0.2%

#### កៅស៊ូផ្តល់ផល

ផ្អាកការចៀរជ័រលើដើមកៅស៊ូឈឺ។ ប្រើថ្នាំ Ridomil សម្រាប់ផ្សិតលើផ្ទាំងមុខចៀរក្នុងកម្រិត 5g/1l ទឹក នៅខែឧសភា-កញ្ញា។




**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រៃកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh



៧. លុបអាចម៍ដីនិងជាន់បង្ហាប់លើកទី៣ រហូតដល់អាចម៍ដីពេញរណ្ដៅជាការសម្រេច។ ក្រោយពេលដាំកូនកៅស៊ូរួចរាល់គេលាតសំបកចង់គ្របគល់ ឬប្រមូលយកចេញពីចម្ការ។



៨. គេលុបដីទុកប្រវែងប្រមាណ ២ធ្នាប់ដៃ ខាងក្រោមភ្នែកបំបៅ រួចដោតក្បាំងឬស្សីចម្ងាយប្រមាណ ០៥-១០ស.មពីកូនកៅស៊ូ ដើម្បីការពារការប៉ះពាល់ដោយសត្វឬការថែទាំ។



កូនកៅស៊ូដាំដោយកូន១ផ័ត្រស្លឹក



កូនកៅស៊ូមានអាយុ ៥ខែ ដាំដោយកូន ១ផ័ត្រស្លឹក


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រៃកលៀប សង្កាត់ព្រៃកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

*មគ្គុទេសក៍បច្ចេកទេស ២០២៤/០៧*


# វិធីដាំកូនកៅស៊ូផ័ត្រ



*ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*
*ការិយាល័យដាំដុះនិងការពារ*

## វិធីដាំកូនកៅស៊ូផ័ត្រ



១. រណ្ដៅដាំកូនកៅស៊ូជីកទំហំ ០.៥០ម x ០.៥០ម x ០.៥០ម។ ពេលកាប់រណ្ដៅ ដីស្រទាប់លើដាក់ទៅម្ខាង ឯស្រទាប់ក្រោមដាក់ទៅម្ខាងទៀត។ នៅពេលលុបរណ្ដៅ យកដីស្រទាប់លើលុបជាមុន ទើបយកស្រទាប់ក្រោមលុបបំពេញរណ្ដៅ។



២. រោយជី NPK 15-15-15 ប្រមាណ ១០០ក្រាម ជាមួយអាចម៍ដីជុំវិញមាត់រណ្ដៅ រួចជ្រួយអោយសព្វល្អ។



៣. កាត់បាតថង់ប្រមាណ ១ស.ម (ក្នុងករណីនេះត្រូវប្រុងប្រយ័ត្ន ជៀសវាងកុំអោយបាក់ខ្នែងកូនកៅស៊ូដែលដុះ និងបែកដីក្នុងថង់)។



៤. លើកកូនកៅស៊ូដាក់ចូលទៅក្នុងរណ្ដៅ ដោយដាក់ភ្នែកបំបៅដែលដុះខ្នែងចេញមកបែរទៅទិសនិរតី ដើម្បីជួយការពារកុំឱ្យងាយបាក់រយះដោយសារខ្យល់ ហើយវះថង់តាមបណ្ដោយពីក្រោមមក លើត្រឹម ១,៣ថង់ ដោយប្រយ័ត្នកុំឱ្យបែកដី។



៥. ដៃទាំងពីរចាប់លាត់ថង់ឡើងលើត្រឹម ១,៣ នៃថង់ កាយអាចម៍ដីដែលលាយច្របល់ជាមួយជីលុបជុំវិញ រួចជាន់បង្ហាប់ដីកូនកៅស៊ូអោយហាប់ណែនល្អ។ គេចាប់លាត់ថង់ លុបអាចម៍ដី និងជាន់បង្ហាប់លើកទី២ នៅប្រវែង ២,៣ ពីបាតថង់។



៦.ចាប់លាត់ថង់ដោយថ្នមៗចេញទាំងស្រុង។

**ខ) ឆ្នាំទី២**

- ត្រូវជំរះតាមរងកៅស៊ូឱ្យបាន១ម៉ែត្រពីគល់កៅស៊ូ
- គ្រប់គ្រងចន្លោះរងឱ្យបានល្អ (ត្រូសល្បាស់ព្រៃឱ្យខ្លី ឬអាចធ្វើដំណាំចន្លោះរង)
- កាត់ខ្នែងកូនកៅស៊ូរហូតដល់កំពស់ ២.៥ម
- គ្របគល់កូនកៅស៊ូ (សំណល់រុក្ខជាតិមានដូចជាដើមសណ្តែក ចំបើង...)
- ជួសកូនកៅស៊ូដែលងាប់ដោយប្រើកូនកៅស៊ូថ័ត្រធំល្អ ដើម្បីដុះលូតលាស់ទាន់គ្នា
- ដាក់ជីតាមគំពេង

ក្នុងការសម្អាតស្មៅតាមរងកៅស៊ូ គេអាចប្រើថ្នាំសម្លាប់ស្មៅបាន ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។

**គ) ឆ្នាំទី៣**

- ត្រូវជំរះតាមរងកៅស៊ូឱ្យបាន១ម៉ែត្រពីគល់កៅស៊ូ
- គ្រប់គ្រងចន្លោះរងឱ្យបានល្អ (ត្រូសល្បាស់ព្រៃឱ្យខ្លី ឬអាចធ្វើដំណាំចន្លោះរង)
- កាត់ខ្នែងកូនកៅស៊ូរហូតដល់កំពស់ ២.៥ម
- ដាក់ជីតាមគំពេង
- បាញ់ថ្នាំការពារ-ព្យាបាលជំងឺផ្កាកុលាប បើសិន

**ឃ) ឆ្នាំទី៤**

- បាញ់ថ្នាំសម្លាប់ស្មៅតាមរងកៅស៊ូចំនួន២ដង
- ដាក់ជីតាមគំពេង
- បាញ់ថ្នាំការពារ-ព្យាបាលជំងឺផ្កាកុលាប
- ត្រូសល្បាស់ព្រៃនៅចន្លោះរងឱ្យបាន២-៣ដងក្នុងមួយឆ្នាំទៅតាមល្បាស់តិច ឬច្រើន

**ខ) ឆ្នាំទី៥ និងទី៦ ឬទី៧**

- ត្រូវថែទាំដូចគ្នានឹងឆ្នាំទី៤ដែរ។ នៅឆ្នាំទី៥ មានពូជកៅស៊ូ (ក្លូន) ខ្លះអាចបើកមុខចៀរជ័របាន។ ឯឆ្នាំទី៦គឺជាឆ្នាំដែលស្ទើរតែគ្រប់ពូជកៅស៊ូទាំងអស់ត្រូវបានបើកមុខចៀរយកជ័រ បើសិនជាដាំបានត្រឹមត្រូវតាមបច្ចេកទេស។

*ឥឡូវនេះ ក្នុងការសម្អាតស្មៅ គេច្រើននិយមប្រើថ្នាំសម្លាប់ស្មៅក្នុងការថែទាំចម្ការកៅស៊ូមិនទាន់ផ្តល់ផល។ ទោះជាយ៉ាងណាក្តីក៏មិនត្រូវប្រើដោយប្រថុយដែរ គឺត្រូវធ្វើតាមបច្ចេកទេស។*

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២២/០៨

# របៀបថែទាំកូនកៅស៊ូ

## ក្រោយពេលដាំរហូតបើកមុខចៀរ



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យជំងឺនិងការពារ

## របៀបថែទាំកូនកៅស៊ូ

កូនកៅស៊ូចាប់ពីដាំរហូតដល់ឆ្នាំដែលគេសន្និដ្ឋានថា មានលក្ខណៈអាចចៀរជ័របានត្រូវបានសន្មតថានៅក្នុងវ័យមិនទាន់ផ្តល់ផល ដែលមានអាយុពី៥ ដល់៧ឆ្នាំទៅតាមពូជ ប្រភេទក្លូន របៀបដាំ ជីជាតិដី និងបច្ចេកទេសថែទាំ។

ក្នុងវ័យមិនទាន់ផ្តល់ផលនេះ ត្រូវដាក់ជីឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ គុណភាព ថែទាំឱ្យបានដិតដល់ និងធ្វើឱ្យវាមានដើមដងសម្រាប់ស្រួលចៀរយកជ័របានពេញលេញទៅថ្ងៃក្រោយ។

នៅប្រទេសកម្ពុជាយើង ដែលមានភាពរាំងស្ងួតរយៈពេលច្រើនខែ ចាប់ពីឆ្នាំដាំទៅ ត្រូវធ្វើយ៉ាងណាកុំឱ្យស្មៅព្រៃប្រជែងដណ្តើមទឹក-ជីជាមួយនឹងកូនកៅស៊ូ និងកុំឱ្យទឹកនោះធាប់ហួតចេញពីដី។ ពន្លឺក៏ត្រូវឱ្យចូលគ្រប់គ្រាន់សម្រាប់ឱ្យកូនកៅស៊ូលូតលាស់បានល្អដែរ។

ទន្ទឹមនេះ កូនកៅស៊ូក្នុងវ័យនេះត្រូវការធាតុចិញ្ចឹមជាចាំបាច់សម្រាប់ការលូតលាស់ ជាពិសេសជាតុអាសូត(N) ហ្វូស្វាត (P) និងប៉ូតាស្យូម(K)។ ស្មៅព្រៃអាចជាគូប្រជែងដណ្តើមជាតុចិញ្ចឹមពីកូនកៅស៊ូដែលជាហេតុនាំឱ្យកូនកៅស៊ូនៅក្រិន។

ក្នុងឆ្នាំទី១ដល់ឆ្នាំទី៦ក្រោយពេលដាំ ត្រូវមើលថែទាំកូនកៅស៊ូដូចតទៅនេះ

**ក) ឆ្នាំទី១**

**១. ការសម្អាតស្មៅ**

បន្ទាប់ពីដាំកូនកៅស៊ូរួច ត្រូវជម្រះស្មៅតាមរងកូនកៅស៊ូឱ្យបាន១ម៉ែត្រយ៉ាងតិចពីគល់កូនកៅស៊ូ។ ក្នុងការជម្រះស្មៅតាមរងកូនកៅស៊ូនេះគេច្រើនជម្រះ ២៥-៣០ថ្ងៃម្តងនៅក្នុងរដូវភ្លៀង។ នៅក្នុងឆ្នាំដំបូង គេអាចជម្រះស្មៅដោយប្រើកម្លាំងកម្មករឱ្យជម្រះនឹងចប គឺមិនប្រើថ្នាំសម្លាប់ស្មៅទេ ព្រោះកូនកៅស៊ូនៅក្មេងខ្ចី លើកលែងតែគេអាចគ្រប់គ្រងបានម៉ត់ចត់។



**២. គ្របគល់**

នៅចុងរដូវភ្លៀង ខែតុលាឬដើមខែវិច្ឆិកា គេអាចយកសំណល់រុក្ខជាតិ ដូចជា ចំបើង ស្លឹកឈើ ដើមសណ្តែក ឬដើមអំបូរលេគុយមីណឹដែលដាំតាមចន្លោះរងមកគ្របជុំវិញគល់ដើម្បីការពារកុំឱ្យទឹកហួតធាប់ ហើយដើមរុក្ខជាតិដែលគេយកមកគ្របគល់នេះអាចរលួយទៅជាជីធម្មជាតិ។

**៣. ជួសកូនដែលងាប់**

បើមានកូនកៅស៊ូណាងាប់ ត្រូវដាំជួសឱ្យអស់និងទាន់ក្នុងឆ្នាំទី១នេះទើបល្អប្រសើរ។

**៤. កាត់ខ្នែង**

ការងារនេះត្រូវចាប់ផ្តើមធ្វើតាំងពីក្រោយពេលដាំ ដើម្បីកុំឱ្យកូនកៅស៊ូធាប់បែកមែក ដោយដើរត្រួតពិនិត្យមើល១៥ថ្ងៃម្តង។

**៥. ដាក់ជីក្រោយពេលដាំ**

ជីត្រូវដាក់ទៅតាមគំពេងដែលបានកំណត់ តាមធម្មតាក្រោយពេលដាំរួចត្រូវដាក់នៅចុងរដូវភ្លៀងម្តងទៀត។ ក្នុងមួយឆ្នាំត្រូវដាក់ជី២ដងគឺដើមរដូវភ្លៀងម្តង(ខែឧសភា)និងចុងរដូវភ្លៀងម្តងទៀត(ខែតុលា)។

**៦. ការគ្រប់គ្រងចន្លោះរង**

នៅចន្លោះរង កសិករអាចដាំដំណាំប្រចាំឆ្នាំដូចជា៖ សណ្តែក...ដែលជួយធ្វើឱ្យដីមានជីជាតិពិសេសអាសូត។ ក្នុងករណីពុំមានដំណាំចន្លោះរងទេត្រូវត្រូសល្បាស់ព្រៃឱ្យខ្លី។



**៧. ការពារភ្លើងឆេះ**

ត្រូវធ្វើផ្លូវភ្លើងព័ទ្ធជុំវិញចម្ការ ដើម្បីការពារភ្លើងឆេះកូនកៅស៊ូនៅរដូវប្រាំង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបច្ចេកទេស ២០២៤/០៩

# ការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផល
# Fertilizer application on mature rubber



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

## ១. សេចក្តីផ្តើម

ការប្រើប្រាស់ជីគឺជាកត្តាសំខាន់ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការលូតលាស់និងទិន្នផលកៅស៊ូ ទន្ទឹមនឹងនោះការវិនិយោគទុនដើម្បីដាំដំណាំកៅស៊ូក៏មានអត្រាកាន់តែខ្ពស់ដែរ។ ដូច្នេះការកំណត់បរិមាណនៃការប្រើប្រាស់ជីមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការសន្សំសំចៃទុននៅក្នុងរយៈពេលដើមកៅស៊ូមិនទាន់ផ្តល់ផលនិងកៅស៊ូផ្តល់ផល។ ការដាំដុះនិងលូតលាស់របស់ដើមកៅស៊ូមានតម្រូវការជីវជាតិគ្រប់មុខទាំងអស់រួមមាន N, P, K, Mg, Ca, S, Fe, Cu, Zn, Mo, Bo, ...តម្រូវការជីវជាតិនេះមានលក្ខណៈខុសៗគ្នាទៅនឹងរុក្ខជាតិផ្សេងៗទៀត ប៉ុន្តែសម្រាប់ដំណាំកៅស៊ូត្រូវការ N, P, K និង Mg ហើយសារធាតុផ្សេងៗទៀតសឹងតែមានគ្រប់គ្រាន់នៅក្នុងដី។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថាដំណាំកៅស៊ូត្រូវការជីច្រើនដើម្បីលូតលាស់បានល្អក្នុងរយៈពេលមិនទាន់ផ្តល់ផល ប៉ុន្តែក៏មិនមានឥទ្ធិពលលើការលូតលាស់ដើម ចំពោះកៅស៊ូផ្តល់ផលទេ។ ទោះបីយ៉ាងណាក៏ដោយ គឺត្រូវពិនិត្យទៅលើការប្រើប្រាស់ជីដោយសន្សំសំចៃ ដើម្បីទទួលផលចំណេញ។




## ២. វិធីសាស្ត្រគណនាបរិមាណជីត្រូវប្រើ

១. ការគិតពិចារណាលើស្ថានភាពជីវជាតិ Nutrient ត្រូវផ្អែកលើសារធាតុសំខាន់ៗដូចជា N, P, K និង Mg ដែលមាននៅក្នុងដីនិងស្លឹក។ ការគិតពិចារណាបន្ថែមទៀតទៅលើស្ថានភាពជីវជាតិត្រូវផ្អែកលើប្រភេទដីអាស៊ីតឬដីបាសដែលមាននៅក្នុងមមោគ។

២. មូលដ្ឋានគ្រឹះនិងលក្ខណៈវិទ្យាសាស្ត្រនៃការបង្កើតអនុសាសន៍ប្រើប្រាស់ជីត្រូវផ្អែកលើកត្តាដូចខាងក្រោមៈ

ក- ការវិភាគដីនិងស្លឹករួមមាន ការវិភាគសារធាតុសរុបទាំងអស់ដូចជា N, P, K និង Mg ដែលមានក្នុងស្លឹកនិងវិភាគ pH, C, N, P, K, Mg បំរែបំរួល P បន្ទាស់ ប្តូរ K និង Mg ដែលមានក្នុងដី។

ខ- ទិន្នផលកៅស៊ូយោងទៅតាមសមត្ថភាពផលិតនៃក្លូន ប្រព័ន្ធចៀរជ័រនិងការប្រើប្រាស់ថ្នាំរំញោច

គ- ការលូតលាស់និងគុណភាពចម្ការកៅស៊ូរួមមាន កំណើននៃការលូតលាស់ទំហំដើមកៅស៊ូផ្តល់ផល ចំនួនដើមចៀរដែលមានគុណភាពខ្ពស់ ចង្វាក់ចៀរជ័រក្នុងមួយឆ្នាំ បច្ចេកទេសនៃការចៀរជ័រ ស្ថានភាពមុខចៀរ ស្ថានភាពការណូពី (Canopy) ស្លឹកកៅស៊ូ ផលប៉ះពាល់នៃជំងឺទៅលើទិន្នផល

ឃ- ទម្រង់នៃការដាក់ជីលើចម្ការកៅស៊ូមានដូចជាប្រភេទ កម្រិតនៃការប្រើប្រាស់ជី ចំនួននៃការដាក់ជីក្នុងមួយឆ្នាំ និងបច្ចេកទេសនៃការដាក់ជី...

ង- បទពិសោធន៍និងជំនាញនៃការប្រើប្រាស់ជីរួមផ្សំជាមួយនឹងកត្តាដែលមានឥទ្ធិពលលើទិន្នផលនិងការកែសម្រួលកម្រិតនិងចំនួនការប្រើប្រាស់ជីនិងកត្តាឥទ្ធិពលផ្សេងៗទៀត។



## ៣. ផ្ទាំងមុខចៀរឆ្លើយតបទៅនឹងការប្រើប្រាស់ជី




- (ពណ៌ទឹកក្រូច) មេតាបូលីសអតិបរិមា ការផ្តល់ជាតិស្ករខ្ពស់ ការប្រើប្រាស់ជីមានប្រសិទ្ធភាពខ្ពស់ (LD ++, +, = +)
- (ពណ៌ខៀវ) ការផ្តល់ជាតិស្ករមានកម្រិត ការប្រើប្រាស់ជីបានផ្តល់ផលមធ្យម (LD =, = –)
- × មេតាបូលីសមានកម្រិតទាប ការប្រើប្រាស់ជីមិនសូវមានប្រសិទ្ធភាព (LD =, = –)
- Δ មេតាបូលីសមានកម្រិតទាបបំផុត ការប្រើប្រាស់ជីមិនមានប្រសិទ្ធភាព (LD –, – –)

សំគាល់: DL= Latex Diagnosis

## ៤. តារាងការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផល

| ឆ្នាំចៀរ | N equivalent (ក្រាម/ដើម) | P2O5 equivalent (ក្រាម/ដើម) | K2O equivalent (ក្រាម/ដើម) | MgO equivalent (ក្រាម/ដើម) |
|---|---|---|---|---|
| 1 | - | 47 | - | - |
| 2 | 97 | 68 | 54 | 18 |
| 3 | 110 | 72 | 72 | 24 |
| 4 | 138 | 90 | 72 | 24 |
| 5 | 120 | 108 | 96 | 36 |
| 6 | 101 | 99 | 120 | 36 |

## ៥. អនុសាសន៍នៃការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផល

– តម្រូវការជីនៃតំបន់មួយគឺពឹងផ្អែកលើលទ្ធផលវិភាគ ដី ស្លឹក អាយុដើមកៅស៊ូ ក្លូន ការលូតលាស់ដង់ស៊ីតេកាណូពី និងលក្ខណៈសំខាន់ដទៃទៀត រួមមាន ប្រវត្តិនៃដំណាំកៅស៊ូ ការដាក់ជីពីអតីតកាល ទម្រង់និងវាយនភាពដី ដើម្បីវាយតម្លៃពីបរិមាណ និងចំនួនដងនៃការប្រើប្រាស់ជី

– ការប្រើជីលើកៅស៊ូផ្តល់ផលមិនមានឥទ្ធិពលលើការលូតលាស់ដើមកៅស៊ូទេ

– ការប្រើជីលើកៅស៊ូផ្តល់ផលដែលមានលក្ខណៈសេដ្ឋកិច្ចគឺពេលផ្ទាំងមុខចៀរមានមេតាបូលីសអតិបរិមា ការផ្តល់ជាតិស្ករខ្ពស់

– ការប្រើជីលើកៅស៊ូផ្តល់ផលដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ត្រូវអនុវត្តលើផ្ទាំងមុខចៀរឆ្លើយតបទៅនឹងការប្រើប្រាស់ជី។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រៃកលៀប សង្កាត់ព្រៃកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

## ៥. ការគ្រប់គ្រងជំងឺ

ការបាញ់ថ្នាំសម្លាប់ផ្សិត គឺជាយុទ្ធសាស្ត្រមួយដែលគេនិយមក្នុងការគ្រប់គ្រងជំងឺ SALB ។

ថ្នាំសម្លាប់ផ្សិតចាស់ៗជាច្រើន (chlorothalonil, propineb, mancozeb, benomyl) និងថ្នាំសម្លាប់ផ្សិតតាមប្រព័ន្ធ (systemic fungicides) ថ្មីៗ (triadimephon, thiophanate methyl, prochloraz, propiconazole, triadimenol និង azoxystrobin) គឺមានប្រសិទ្ធភាព ។ ថ្នាំសម្លាប់ផ្សិតទាំងនេះ ត្រូវបានបាញ់ពីលើអាកាសដោយយន្តហោះ ឬ បាញ់ពីដីដោយម៉ាស៊ីនបាញ់ថ្នាំ ។ ការប្រើថ្នាំសម្លាប់ផ្សិតតាមប្រព័ន្ធយូរៗទៅ អាចនាំឲ្យកើតមានពូជផ្សិតដែលធន់នឹងថ្នាំសម្លាប់ផ្សិត ។ កាលពីមុន ក្លូនដែលធ្លាប់ហៅថា "**ក្លូនធន់**" ត្រូវបានឆ្លងជំងឺនៅពេលដែលពូជថ្មីនៃផ្សិត *M. ulei* កើតឡើង ។



## ៦. ការគំរាមកំហែងនៃជំងឺ SALB នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក

ជំងឺជាច្រើន ជាឧទាហរណ៍ ជំងឺ late blight (ដំឡូងបារាំង), ជំងឺ rust (កាហ្វេ) និងជំងឺ Dutch elm បានឆ្លងកាត់មហាសមុទ្រ និងកើតមាននៅក្នុងតំបន់ថ្មី ។ ការរាលដាលនេះ ត្រូវបានសន្មតថាតាមរយៈស្ព័រសោត់តាមខ្យល់ ឬ ការនាំចូលរុក្ខសម្ភារដែលឆ្លងជំងឺ ។ ហេតុនេះ ជំងឺ SALB គឺជាការគំរាមកំហែងមួយដល់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដោយសារគមនាគមន៍កើនឡើងរវាងប្រទេសដែលមានកើតជំងឺតំបន់ (SALB) និងប្រទេសដាំដុះកៅស៊ូនៅក្នុងតំបន់ ។ គេបានព្យាករណ៍ថា ដំណាំកៅស៊ូនៅអាស៊ីអាគ្នេយ៍នឹងត្រូវបានបំផ្លាញក្នុងរយៈ ៥-៧ឆ្នាំ ក្រោយពេលដែលជំងឺ SALB ត្រូវបាននាំចូល ដោយសារលំនាំដាំនៅជិតគ្នា បរិស្ថានអំណោយផលទៅនឹងជំងឺ និងក្លូនដែលងាយទទួលរងជំងឺនេះ ៕

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១០

# ជំងឺជ្រុះស្លឹកអាមេរិកខាងត្បូង (SALB) នៃដំណាំកៅស៊ូ



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះ-ការពារ

## ១. សេចក្តីផ្តើម

ជំងឺជ្រុះស្លឹកអាមេរិកខាងត្បូង (SALB) ជាជំងឺដ៏គ្រោះថ្នាក់បំផុតនៃដំណាំកៅស៊ូ ដោយសារផលបំផ្លិចបំផ្លាញរបស់វា ។ តាមសាវតារ ជំងឺ SALB បានបំផ្លាញចម្ការកៅស៊ូជាច្រើន ដែលបានបង្កើតឡើងក្នុងបណ្តាទសវត្សឆ្នាំ១៩៣០ នៅអាមេរិកកណ្តាល និងអាមេរិកខាងត្បូង ។ បណ្តាប្រទេសដាំកៅស៊ូនៅអាស៊ី ដែលផលិតច្រើនជាង៩០% នៃកៅស៊ូធម្មជាតិពិភពលោក មានការព្រួយបារម្ភជាខ្លាំងចំពោះការគំរាមកំហែងនៃជំងឺ SALB ។ មូលហេតុដែលនាំឱ្យមានការបារម្ភចំពោះជំងឺនេះ គឺដោយសារលក្ខខណ្ឌអាកាសធាតុនៅក្នុងប្រទេសផលិតកៅស៊ូសំខាន់ៗទាំងនោះ អាចប្រកបនឹងការបង្កជំងឺ SALB ដ៏សាហាវនេះ ។

## ២. ភ្នាក់ងារបង្កជំងឺ

ជំងឺ SALB ត្រូវបានបង្កឡើងដោយផ្សិតដែលមានឈ្មោះ *Microcyclus ulei* ។ ផ្សិតនេះបង្កើតស្ព័របីប្រភេទ ដូចជា conidia, pycnospores និង ascospores ។




## ៣. រុក្ខជាតិដែលទទួលជំងឺ

ផ្សិត *M. ulei* បង្កជំងឺតែលើពួក *Hevea* ប៉ុណ្ណោះ ។ *Hevea* មានចំនួន ១១ ប្រភេទ ប៉ុន្តែផ្សិត *M. ulei* បង្កជំងឺតែលើ *Hevea* ចំនួន ៥ ប្រភេទប៉ុណ្ណោះ គឺ *H. brasiliensis, H. spruceana, H. guianensis, H. Benthamiana* និង *H. Camporum* ។

## ៤. សញ្ញាជំងឺ

ផ្សិតនេះបង្កជំងឺតែលើផ្នែកខ្ចីនៃរុក្ខជាតិ ។



សញ្ញាដំបូងនៃការបង្កជំងឺ គឺការខូចទ្រង់ទ្រាយនៃកូនស្លឹកទាំងឡាយ ជាយថាហេតុកូនស្លឹកដែលឆ្លងជំងឺធ្ងន់ធ្ងរក៏ឡើងក្រៀមស្ងួត ហើយប្រែពណ៌ហាក់ដូចជាខ្មៅ ។



ជាលិកាស្លឹកនៅចំកណ្តាលនៃលេស្យុង ក្លាយជារលួយ ហើយប្រែជាពណ៌សដូចក្រដាស ហើយក្រោយមកទៀតក៏រហែក ដែលបន្សល់ទុករន្ធប្រហោងនៅលើស្លឹក ។



កូនស្លឹកដែលកើតជំងឺធ្ងន់ធ្ងរ ក៏ជ្រុះមកដី រីឯទងស្លឹកនៅសល់ជាប់នឹងមែកមួយរយៈ ប៉ុន្តែពួកវានឹងជ្រុះនៅពេលបន្ទាប់ជាយថាហេតុ ។



មែកដែលឆ្លងជំងឺ អាចងាប់ពីចុង ។ ដើមដែលកើតជំងឺធ្ងន់ធ្ងរ នឹងមានកញ្ចុំមែកស្លឹកតិចជាមួយមែកងាប់ ។

ផ្សិត *M.ulei* ក៏បង្កជំងឺផងដែរនៅលើទងស្លឹក មែកខ្ចី កញ្ចុំផ្កាផ្កា និង ផ្លែខ្ចី ។



## ២. កំហាប់នៃថ្នាំរំញោច

ចំពោះកំហាប់ 2,5% នៃល្បាយថ្នាំរំញោច ដែលត្រូវលាប បរិមាណកំណត់ជាមធ្យម គឺ១ក្រាម សម្រាប់លាបមួយដើម សម្រាប់ការចៀរពាក់កណ្តាលគូទខ្យង (S/2)។ ករណីចៀរឡើងលើ (S/4U) ឬ ចៀរសម្ងាប់ដើមចុងក្រោយ ល្បាយថ្នាំរំញោចអាចមានកំហាប់អេតេហ្វូន 5%។

*ដើម្បីចៀសវាងការរំញោចលើសកម្រិតបរិមាណដែលបានកំណត់នៃរូបធាតុសកម្ម (ជាមីលីក្រាមសម្រាប់មួយដើមក្នុងមួយឆ្នាំ) មិនត្រូវឱ្យលើសជាដាច់ខាត។ បរិមាណនេះ គឺអាស្រ័យទៅតាមក្រុមក្លូនកៅស៊ូនិងប្រព័ន្ធចៀរ។*

## ៣. ចំនួនជង (Rounds) នៃការរំញោច

ការរំញោចមួយលើក ទៅមួយលើកទៀត ត្រូវមានគម្លាតពេលគ្រប់គ្រាន់ ដើម្បីទុកឱ្យដើមកៅស៊ូមានពេលអាចបង្កើតទឹកជ័រឡើងវិញ ស្របទៅតាមបរិមាណថ្នាំនិងប្រព័ន្ធចៀរដែលគេប្រើ។ ការរំញោចនេះត្រូវធ្វើច្រើនដង ឬ តិចក្នុងមួយឆ្នាំ គឺអាស្រ័យទៅតាមក្រុមក្លូន (Clonal typology)។

## ៤. ពេលត្រូវរំញោច

- ការរំញោចត្រូវប្រព្រឹត្តទៅឱ្យបានមុនការចៀរជ័រពី២៤-៤៨ម៉ោង អាស្រ័យតាមចង្វាក់ចៀរ។

*ការរំញោចលើសកំណត់ អាចធ្វើឱ្យមានវិបត្តិដល់សរីរៈនៃដើមកៅស៊ូនិងបណ្តាលឱ្យដើមកៅស៊ូអន់ខ្សោយ ដែលអាចនាំឱ្យសម្បកស្ងួត ទឹកជ័រលែងហូរ និងនាំឱ្យមានបាតុភូតដែលគេហៅថា"**ស្ងួតមុខចៀរ**" (Tapping Panel Dryness)។*

## ការប្រុងប្រយ័ត្ន

ក្នុងការរំញោច ត្រូវប្រុងប្រយ័ត្នដូចតទៅ ៖

- ★ ត្រូវចៀសវាងធ្វើការរំញោចក្នុងពេលដែលដើមកៅស៊ូកំពុងជ្រុះនិងដុះស្លឹកឡើងវិញ
- ★ មិនត្រូវលាបថ្នាំរំញោចនៅពេលភ្លៀង
- ★ ត្រូវរក្សាទុក ឬដឹកជញ្ជូនល្បាយសារធាតុរំញោចនៅក្នុងធុងមិនមែនលោហៈ។

*សូមទាក់ទងជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បើលោក-អ្នកចង់ដឹងលម្អិតអំពីការរំញោច។*

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១១

# ការរំញោចទឹកជ័រ ដោយប្រើអេតេហ្វូន



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យសរីរវិទ្យានិងអាជីវកម្ម

## និយមន័យការរំញោច (Stimulation)

ការរំញោច គឺជាវិធីប្រើផលិតផលគីមីដើម្បីទាញយកទឹកជ័រឱ្យបានច្រើន ដោយវាមិនធ្វើឱ្យមុខសរសៃជ័រឆាប់ស្ទះ និងធ្វើឱ្យទឹកជ័រហូរចេញបានយូរ។ ជាលទ្ធផល ការរំញោចធ្វើឱ្យកសិករទទួលបានជ័រកៅស៊ូច្រើន ដោយពុំចាំបាច់បង្កើនប្រវែងមុខចៀរឬចង្វាក់ចៀរ។ល។

## អត្ថប្រយោជន៍នៃការរំញោច

ការរំញោចនឹងជួយ ៖

- ➢ បង្កើនបរិមាណទឹកជ័រនៃអ្នកចៀរជ័រ ហើយស្របគ្នានោះប្រាក់កម្រៃរបស់អ្នកចៀរក៏កើនឡើង។
- ➢ ការចំណាយសម្បកអស់តិចៗ ព្រោះហេតុនេះបានជាដើមកៅស៊ូមានរយៈពេលចៀរយកជ័របានយូរឆ្នាំ។
- ➢ បន្ថយចង្វាក់ចៀរ ប៉ុន្តែអាចយកផលបានដូចចង្វាក់ញឹក ឬ បានច្រើនជាង។ ដូចនេះ គេប្រើកម្មករចំនួនតិចដែលធ្វើឱ្យសោហ៊ុយចំណាយក្នុងការប្រមូលផលថយចុះ ឯទិន្នផលនៅដដែល។
- ➢ ពន្យារការចៀរសម្បកដែលដុះថ្មីឡើងវិញ។ ដូច្នេះ សម្បកដែលដុះថ្មីនេះ មានលក្ខណៈពេញលេញ ហើយមានសភាពល្អប្រសើរ។

## អំពីល្បាយថ្នាំរំញោច

សព្វថ្ងៃថ្នាំរំញោចដែលគេនិយមប្រើច្រើនជាងគេគឺ "**អេតេហ្វូន** - Ethephon" ឬ ឈ្មោះគីមីហៅថា ***អាស៊ីត ២ ក្លរ៉ូអេទីល - ផូស្វូនិក*** (2 chloroethyl-phosphonic acid)។ គេអាចស្គាល់ផងដែរនូវថ្នាំរំញោចនេះ ក្រោមឈ្មោះ "**អេត្រែល** - Ethrel" ។

អេតេហ្វូនត្រូវបានលាបក្រោមរូបភាពជាល្បាយជាមួយទឹក ឬ ប្រេង (ដូងប្រេង)។ លើទីផ្សារអាចមានល្បាយដែលមានកំហាប់ផ្សេងៗ (2,5%, 5%,...)។

## ការរំញោច

ការរំញោចមានច្រើនវិធី ប៉ុន្តែវិធីដែលគេច្រើនអនុវត្តគឺវិធីលាបថ្នាំរំញោចដោយប្រើជក់លាប។

### ១. វិធីលាបថ្នាំរំញោច

នៅក្នុងចំណោមវិធីលាបទាំងឡាយ វិធីលាបនៅលើសម្បកដែលដុះឡើងវិញ (panel application) ត្រូវបានគេនិយមប្រើជាងគេ។

ក្នុងករណីនេះ ថ្នាំរំញោចត្រូវបានលាបផ្ទាល់លើមុខចៀរ (tapping cut) ទៅតាមប្រវែងមុខចៀរ (ផ្ទៃលាបមានទទឹងប្រមាណ ១សង់ទីម៉ែត្រ) នៅលើសម្បកដែលដុះឡើងវិញ។

វិធីនេះមានភាពងាយស្រួល ហើយចំណាយតិចៗ ហេតុនេះហើយ វិធីនេះត្រូវបានគេអនុវត្តច្រើនជាងគេ។




មុខចៀរចុះក្រោម




មុខចៀរឡើងលើ

*វិធីលាបលើសម្បកដែលដុះឡើងវិញ*
Panel application (Eric Gohet, 2012)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១២

# របៀបបើកមុខចៀរដំបូង



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យសរីរវិទ្យា-អាជីវកម្ម

## ១.សេចក្តីផ្តើម

ផ្នែកសំខាន់បំផុតនៃដើមកៅស៊ូគឺស្ថិតនៅលើសំបក ដែលនៅខាងក្នុងមានសរីរាង្គផលិតទឹកជ័រ។ អ្នកដាំកៅស៊ូត្រូវយកចិត្តទុកដាក់លើរបៀបបើកមុខចៀរដំបូង។ បើការបើកមុខចៀរដំបូងមិនបានរៀបចំទៅតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវទេ ផលិតកម្មកៅស៊ូនឹងថយចុះ។ ដូច្នេះម្ចាស់ ឬ អ្នកទទួលខុសត្រូវចម្ការកៅស៊ូមានភារកិច្ចរៀបចំបើកមុខចៀរដំបូងអោយបានត្រឹមត្រូវ ទៅតាមបច្ចេកទេសដែលបានកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ។

## ២.ទម្រង់ទូទៅនៃសំបកដើមកៅស៊ូ

នៅក្នុងដើមកៅស៊ូ ទឹកជ័រត្រូវបានផ្ទុកនៅក្នុងសរសៃជ័រ។ ការធ្វើឱ្យសរសៃជ័រដាច់បានបណ្តាលឱ្យទឹកជ័រហូរចេញមកក្រៅ។ ដើមកៅស៊ូត្រូវបានធ្វើអាជីវកម្មដោយការចៀរសំបកក្នុងរយៈពេលវៀងទាត់ តាមមុខចៀរនៅលើដើមជារង្វង់គូទខ្យង។ ចំណេះដឹងអំពីទម្រង់នៃសំបក ដើមកៅស៊ូមានសារសំខាន់ណាស់ ដើម្បីយល់ដឹងអំពីលំហូរនៃទឹកជ័រ។ ភាគច្រើននៃជាលិកាដើមកៅស៊ូ គឺកើតចេញពីដំណើរការនៃមេជាលិកាខាង ដែលគេហៅថា "កំប្បូម (cambium)" ។ ស្រទាប់ "កំប្បូម" នេះបានបង្កើតឱ្យមាននូវ "**សាច់ឈើ**" នៅផ្នែកខាងក្នុងនិង "**ស្រទាប់ស្រាយ**" នៅផ្នែកខាងក្រៅ។ គឺនៅក្នុងស្រទាប់ស្រាយនេះហើយដែលបណ្តាសរសៃទឹកជ័រស្ថិតនៅ។




## ៣.លក្ខណៈវិនិច្ឆ័យនៃការបើកមុខចៀរដំបូង

ដើមកៅស៊ូដែលអាចបើកមុខចៀរបាន ត្រូវមានរង្វង់ដើម ៥០ស.ម នៅកម្ពស់ ១០០ស.ម ពីដី។ ចម្ការដែលអាចចាប់ផ្តើមបើកមុខចៀរលុះត្រាមានចំនួនដើមដែលមានរង្វង់ដូចខាងលើស្មើ៧០%នៃចំនួនដើមទាំងអស់នៅក្នុងចម្ការទើបមានប្រសិទ្ធភាពសេដ្ឋកិច្ច។

## ៤.របៀបបើកមុខចៀរ

ដំបូងត្រូវវាស់និងជ្រើសរើសដើមកៅស៊ូ ដែលមានរង្វង់ដើម ៥០ស.ម នៅកម្ពស់ ១០០ស.ម ពីដី បន្ទាប់មកគេដៅនៅកម្ពស់ ១៧០ស.ម ពីដីនូវសញ្ញា ឬចំណុចសម្គាល់ពណ៌ក្រហមលើដើមដែលមានទំហំត្រូវខ្នាត រួចគូសបន្ទាត់ឈរពីរឈមគ្នាតាមបណ្តោយដើម ដែលមានចំណុចក្រហមសំគាល់នោះ


ការដៅចំណុចសំគាល់ដើម សម្រាប់បើកមុខចៀរ


ការចែកផ្ទាំងសំបកជាពីរផ្នែកស្មើគ្នា

ដើម្បីចែកផ្ទាំងមុខចៀរជាពីរផ្ទាំងប៉ុនគ្នា ដោយដាក់ម៉ែត្រឈើដែលមានប្រវែងពីរម៉ែត្រផ្ទឹបជាប់ ហើយបញ្ឈរស្របនឹងស្ថានភាពដើមអោយចំពាក់កណ្តាល រួចធូតអោយមុតជ្រៅបន្តិចតាមម៉ែត្រឈើ។ គួរកត់សម្គាល់ថា បន្ទាត់ឈរទាំងពីរមានទិសបែរទៅរកបន្ទាត់ទ្រូងនៃរងកៅស៊ូ។

បន្ទាប់មក គេយកឧបករណ៍គំរូក្រិតមុខចៀរ (ទង់ជ័យ) ធ្វើអំពីដែកបន្ទះមកដាក់ផ្ទឹបទៅនឹង


ឧបករណ៍គំរូក្រិតមុខចៀរ


ការក្រិតសំបកសម្រាប់ចៀរ

ដើមកៅស៊ូត្រង់ចំណុចសម្គាល់ ១,៣ម ពីដីរួចគូសគំនូសតាមដែកបន្ទះដើម្បីបង្កើតមុខចៀរ ដែលមានមុំ ៣៥ អង្សា។ ទន្ទឹមនឹងនេះ គេត្រូវក្រិតសំបកសម្រាប់ចៀររយៈពេល ១ខែ ៣ខែ ៦ខែ និងមួយឆ្នាំ។ ចំនៀរចំណាយសំបកក្នុងមួយឆ្នាំចំពោះដើមកៅស៊ូទើបបើកមុខចៀរថ្មី គឺ ១៣ស.ម។

## ៥.ការបំពាក់ឧបករណ៍ត្រងជ័រ

ប្រវែងពីមុខចៀរមកចានត្រងជ័រមានប្រវែង ៣៥ស.ម។ នៅចន្លោះពីមុខចៀរមកស្លាបព្រាមានប្រវែង ១៥ស.ម គេធូតចង្អូររាងជ្រៅបន្តិច ដើម្បីឱ្យទឹកជ័រហូរចុះមកក្រោមកាត់តាមស្លាបព្រារួចស្រក់ធ្លាក់ក្នុងចាន។



ការបំពាក់ស្លាបព្រា លួសចងចាន និងចានត្រងជ័រ

## ៦.ការចាប់ផ្តើមបើកមុខចៀរយកជ័រ

មុននឹងចាប់ផ្តើមដំណើរការចៀរជ័រដំបូង គេត្រូវបើកមុខចៀរចំនួន៣ពន្លាកជាមុនសិន ដោយចៀរតាមលំនាំខ្នាតមុំចំណោតមុខចៀរ ដែលបាន


ការចៀរបើកមុខដំបូង

រៀបរាប់នៅក្នុងរបៀបបើកមុខចៀរខាងលើនិងអនុវត្តតាមជំហានដូចខាងក្រោម:

<u>ពន្លាកទី១</u>: ចៀរសើរៗតាមគំរូចំណោតមុខចៀរ។

<u>ពន្លាកទី២</u>: ចៀរតាមលំនាំនៃពន្លាកទី១អោយបានជ្រៅជាងពន្លាកទី១បន្តិច។

<u>ពន្លាកទី៣</u>: រុញពន្លាកចៀរអោយដល់ជម្រៅតាមបទដ្ឋានដែលបានកំណត់គឺទុក ១ម.ម ពីស្រទាប់ "កំប្បូម (cambium)" ៕

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

**៤. បញ្ហាប្រឈម**

- ជំងឺស្លឹកកៅស៊ូ Pestalotiopsis ជាជំងឺស្លឹកដ៏គ្រោះថ្នាក់និងរាលដាលលឿនបំផុតសម្រាប់ចម្ការកៅស៊ូ
- ជំងឺនេះកើតមានតែលើស្លឹកចាស់នៅចម្ការកៅស៊ូពេញវ័យអាយុចាប់ពី៨ឆ្នាំឡើង (កៅស៊ូប្រមូលផលទឹកជ័រ)
- ជំងឺស្លឹកកៅស៊ូ Pestalotiopsis បណ្តាលឱ្យកៅស៊ូជ្រុះស្លឹកពី៧០-៩០% និងបាត់បង់ទិន្នផលពី ២៥-៥០% ។











**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៥៩E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ៧៨ ៦៨២ ២២២
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១៣

# ជំងឺស្លឹកកៅស៊ូ Pestalotiopsis





ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

**១. ប្រវត្តិនៃជំងឺ**

នៅឆ្នាំ២០១៦ ជំងឺ Pestalotiopsis កើតមាននៅភាគខាងជើងកោះស៊ូម៉ាត្រា បន្ទាប់មកនៅឆ្នាំ២០១៧ បានរាតត្បាតដល់ភាគខាងត្បូងកោះស៊ូម៉ាត្រានៃប្រទេសឥណ្ឌូនេស៊ី ហើយបន្តកើតមានរហូតដល់បច្ចុប្បន្ន។ ជំងឺនេះបានរាលដាលដល់ប្រទេសម៉ាឡេស៊ី នៅឆ្នាំ២០១៧ និងប្រទេសថៃនៅឆ្នាំ២០១៩។ ឆ្នាំ២០២០ ជំងឺ Pestalotiopsis បានកើតមាននៅប្រទេសផលិតកៅស៊ូធម្មជាតិចំនួន៥ គឺប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ឥណ្ឌា ស្រីលង្កា និងថៃ ហើយត្រូវបានប្រកាសអាសន្ននៅក្នុងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ ឆ្នាំ២០២១ ជំងឺ Pestalotiopsis បានរាលដាលដល់ប្រទេសវៀតណាមនិងប្រទេសកម្ពុជា។ ក្នុងប្រទេសកម្ពុជាជំងឺនេះត្រូវបានឃើញកើតមាន នៅស្រុកបុទុមសាគរ ខេត្តកោះកុង។

**២. រោគសញ្ញាជំងឺ**

ជំងឺស្លឹកកៅស៊ូ Pestalotiopsis បង្កឡើងដោយផ្សិត *Pestalotiopsis* species។ ជំងឺកើតលើស្លឹកកៅស៊ូចាស់(កៅស៊ូចាប់ពីអាយុ៨ឆ្នាំឡើង)។



រោគសញ្ញាកើតលើស្លឹកគឺមានស្នាមជាំជារង្វង់នៅផ្នែកខាងក្រោម និងស្នាមអុចតូចៗពណ៌លឿងនៅផ្នែកខាងលើ បន្ទាប់មកស្នាមអុចនេះប្រែទៅជាពណ៌ខ្មៅ ក្រោយមកនៅលើស្លឹកមានរាងជារង្វង់ពណ៌ត្នោតហើយស្ងួត។ ស្លឹកចាប់ផ្តើមប្រែពណ៌ទៅជាលឿង ហើយចាប់ផ្តើមជ្រុះទាំងស្លឹកពណ៌បៃតងនិងស្លឹកពណ៌លឿង។









**៣. ការព្យាបាល**

កៅស៊ូដែលកើតនូវជំងឺនេះ ត្រូវចាំបាច់ធ្វើការព្យាបាលជាបន្ទាន់។ ការព្យាបាល ត្រូវបាញ់ថ្នាំលើកន្សោមស្លឹក និងស្លឹកជ្រុះលើដីចំនួន៣-៦ដង ដោយប្រើថ្នាំគីមីមានដូចជាៈ

- ក្លរ៉ូតាឡូនីល (chlorothalonil)
- ប្រូពីនេប ឬប្រូពីកូណាសូល (propineb or propiconazole)
- បេណូមីល (benomyl) កម្រិត ០,០២%
- ហិចសាកូណាសូល (hexaconazole) កម្រិត ០,៥ លីត្រក្នុងមួយហិកតា
- ម៉ង់កូសែប (mancozeb) កម្រិត ០,២%







## អនុសាសន៍សម្រាប់ការផ្លាស់ប្ដូរមុខចៀរលើសម្បកកំណើត




## ៣. ការផ្លាស់ប្ដូរផ្ទាំងមុខចៀរជ័រ

ការចៀជ័រពាក់កណ្ដាលជុំដើម S/2 នៅលើផ្ទាំងទី១ អនុវត្តចៀរ៦ឆ្នាំគឺចៀរជ័រពីឆ្នាំទី១ទៅដល់ឆ្នាំទី៦។ បន្ទាប់មកចាំបាច់ត្រូវផ្លាស់ប្ដូរពីផ្ទាំងទី១មកចៀរផ្ទាំងទី២វិញ អនុវត្តការចៀរ៨ឆ្នាំទៀតគឺចៀរនៅឆ្នាំទី៧ដល់ឆ្នាំទី១០ បន្តការចៀរនៅឆ្នាំទី១៣ ឆ្នាំទី១៦ ឆ្នាំទី១៩បញ្ចប់ត្រឹមឆ្នាំទី២២។

ការចៀជ័រមុខលើគឺត្រូវចាប់ផ្ដើមបន្តពីការចៀរមុខក្រោមគឺចៀររយៈពេល ២ឆ្នាំដោយចៀរនៅឆ្នាំទី១១ និងឆ្នាំទី១២ នឹងត្រូវផ្អាកចំនួនមួយឆ្នាំដោយប្ដូទៅចៀរមុខក្រោមចំនួន១ឆ្នាំវិញទើបបន្តរចៀរមុខលើ២ឆ្នាំបន្តរបន្ទាប់ទៀត។ (បញ្ជាក់សញ្ញាព្រួញពណ៌ខៀវចុះក្រោម គឺជាការចៀរជ័រមុខក្រោម ចំណែកសញ្ញាព្រួញពណ៌ក្រហមគឺជាការចៀរជ័រមុខលើ)។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀបខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១៥

# អនុសាសន៍ស្ដីអំពីការគ្រប់គ្រងផ្ទាំងមុខចៀរជ័រនៅប្រទេសកម្ពុជា



*ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*
*ការិយាល័យសរីរវិទ្យា-អាជីវកម្ម*

## ១. សេចក្ដីផ្ដើម

ការប្រមូលផលជ័រកៅស៊ូ អាចមានរយៈពេល២៤ឆ្នាំឡើងទៅ ចំពោះការចៀជ័រលើសម្បកកំណើត នឹងអាចបន្តរចៀរលើសម្បកដុះឡើងវិញជាច្រើនឆ្នាំទៀត។ សរីរវិទ្យារបស់កោសិកាទឹកជ័រមានឥទ្ធិពលនឹងទំនាក់ទំនងទៅ និងយុទ្ធសាស្ត្រនៃការគ្រប់គ្រងផ្ទាំងមុខចៀរ ក្នុងអំឡុងពេលចៀរជ័រ តាមដំណាក់កាលនីមួយៗ (Lacote, 2004)។ ការផ្លាស់ប្ដូរផ្ទាំងមុខចៀរ ជាកត្តាមួយផ្ដល់សារៈសំខាន់បំផុត សម្រាប់កៅស៊ូកំពុងប្រមូលផល បច្ចុប្បន្នការផ្លាស់ប្ដូផ្ទាំងមុខចៀរមានលក្ខណៈខុសៗគ្នា អាស្រ័យលើការយល់ឃើញរបស់ម្ចាស់ចំការទាំងកៅស៊ូគ្រួសារ និងកៅស៊ូឧស្សាហកម្មនៅប្រទេសកម្ពុជា។

## ២. ការគ្រប់គ្រងផ្ទាំងមុខចៀរ

ជាទូទៅការចៀជ័រត្រូវចែកចេញជាបីដំណាក់កាលគឺ៖

១.ដំណាក់កាលចៀរជ័រមុខក្រោម (Down-ward Tapping)

២.ដំណាក់កាលចៀជ័រមុខលើ (Upward Tapping)

៣.ដំណាក់កាលចៀជ័រលើសម្បកដុះឡើងវិញ (tapping on renewed bark )

ដើម្បីគ្រប់គ្រងការផ្លាស់ប្ដូរ ផ្ទាំងមុខចៀរប្រកបដោយប្រសិទ្ធភាពខ្ពស់ នឹងដើម្បីឲ្យដើមកៅស៊ូបញ្ចេញជ័រប្រកបដោយសក្ដានុពល ខ្ពស់មុនពេលកាប់ដាំឡើងវិញ នឹងជានិយាមកម្មលើការគ្រប់គ្រងនិងការផ្លាស់ប្ដូរផ្ទាំងមុខចៀរ ចំពោះកៅស៊ូគ្រួសារ និងកៅស៊ូឧស្សាហ៏កម្មនៅប្រទេសកម្ពុជា វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសូមផ្ដល់អនុសាសន៍ស្ដីពី ការគ្រប់គ្រងផ្ទាំងមុខចៀរលើសម្បកកំណើត អនុសាសន៍នេះសម្រាប់អនុវត្តដំណាក់កាលចៀរជ័រមុខក្រោម និងដំណាក់កាលចៀរជ័រមុខលើ។

### ២.១ ដំណាក់កាលចៀរជ័រមុខក្រោម

ការចៀជ័រមុខក្រោម គឺកំណត់តាមលំនាំខ្នាតចំណោតមុខចៀរមុំ៣០អង្សាសេ កម្ពស់មុខចៀរ១៣០ស.មពីដី អនុវត្តចៀរពាក់កណ្ដាលជុំដើមចៀរមួយថ្ងៃសម្រាកពីថ្ងៃ សម្រាប់កៅស៊ូបើកមុខចៀរតំបូង ផ្ដល់លទ្ធភាពឲ្យដើមកៅស៊ូបង្កើតទឹកជ័រឡើងវិញនិងដុះលូតលាស់ល្អ (Compagnon, 1986)។ ទន្ទឹមនឹងនេះ គេត្រូវក្រិតសំបកសម្រាប់ចៀររយៈពេល៣ខែ ៦ខែ និងមួយឆ្នាំ។ ត្រូវចំណាយសំបកក្នុងមួយឆ្នាំគឺ ១២ស.ម។

### ២.២ ដំណាក់កាលចៀរជ័រមុខលើ

ការចៀជ័រមុខលើត្រូវ កំណត់មុំ៤៥អង្សាសេដោយចៀរ S/4 មានន័យថាមួយដើមត្រូវចៀរត្រឹមមួយភាគបួនស្មើ២៥%នៃដើម។ ការចៀរជ័រមុខលើគឺ មានភាពលំបាកជាងការចៀរជ័រមុខក្រោមចាំបាច់អ្នកចៀរជ័រ ត្រូវមានបទពិសោធន៍នឹងទេពកោសល្យច្បាស់លាស់។កម្ពស់មុខចៀរគឺប្រែប្រួលពី ១៣៥ស.មទៅ ២០០ស.ម នៅពេលមុខចៀរជ័រកាន់តែខ្ពស់ តម្រូវការជងពន្ទាកកាន់តែវែង ជួនកាលត្រូវប្រើជណ្ដើរទៀតផង។ ការចំណាយសម្បកចាំបាច់ត្រូវក្រិតការចៀរលើសម្បកសម្រាប់រយៈពេល ៣ខែ ៦ខែ និងមួយឆ្នាំ។ ជាទូទៅត្រូវចំណាយ១៥ស.មក្នុងមួយឆ្នាំ។



ការចៀរជ័រមុខក្រោម ការចៀរជ័រមុខលើ



## ៤. ការការពារជំងឺ

ជំងឺភ្នែកចាប មិនសូវគ្រោះថ្នាក់ទេនៅក្នុងថ្នាលបណ្តុះកូនដែលដីមានជីជាតិគ្រប់គ្រាន់។ ការថែទាំត្រូវបានយកចិត្តទុកដាក់នៅពេលបង្កើតថ្នាលកូន ហើយត្រូវចៀសវាងដីខ្សាច់ខ្លាំងពេក ឬដីគ្រួសថ្ម ដែលអាចធ្វើឱ្យកូនកៅស៊ូងាយរងគ្រោះដោយសារគ្រោះរាំងស្ងួត។



## ៥. ការព្យាបាល

ដើម្បីព្យាបាលជំងឺប្រកបដោយជោគជ័យ ត្រូវបាញ់ថ្នាំសម្លាប់ផ្សិតក្នុងចន្លោះមួយសប្តាហ៍ម្តងនូវប្រភេទថ្នាំដូចជា៖

- ម៉ង់កូសែប (Mancozeb) ក្នុងកម្រិត ០,២%
- ប្រូពីនែប (Propineb) ក្នុងកម្រិត ០,២%
- កាបិនដាស៊ីម (Carbendazim)ក្នុងកម្រិត០,០២%
- ឌីទីអូកាបានមាត(Dithiocarbamate)ក្នុងកម្រិត ២%
- បាវីសស្ទីន (Bavistin) ក្នុងកម្រិត ០,៤មីលីលីត្រ /១លីត្រទឹក។ល។




**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៥៩E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ៧៨ ៦៨២ ២២២

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២៤/១៦


# ជំងឺភ្នែកចាប
# Bird"s eye spot leaf disease




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ


## ១. លក្ខណៈទូទៅ

ជាទូទៅជំងឺភ្នែកចាប (Bird’s eye spot disease) តែងតែកើតមានឡើងនៅក្នុងថ្នាលបណ្តុះកូន អំឡុងពេលនៃអាកាសធាតុស្ងួត។ ជំងឺប្រភេទនេះមានកើតច្រើននៅលើកៅស៊ូ ហើយវាមិនបណ្តាលឱ្យដើមកៅស៊ូងាប់ទេ ប៉ុន្តែវាអាចធ្វើឱ្យដើមកៅស៊ូទាំងមូលចុះខ្សោយនិងជ្រុះស្លឹក។ កូនកៅស៊ូដែលកើតជំងឺនេះដុះលូតលាស់យឺតយ៉ាវក្រុបានយកទៅដាំឬក្របានបំប៉ៅ។ ភាគច្រើនវាកើតនៅលើដើមកៅស៊ូដែលដាំនៅលើដីខ្វះជីជាតិ ។

## ២. រោគសញ្ញាជំងឺ

ជំងឺភ្នែកចាបមានស្នាមអុជរាងមូលទំហំ ១-៣ម.ម. មានចំណុចភ្លឺថ្លានៅចំកណ្តាល និងព័ទ្ធជុំវិញដោយរឹមតូចពណ៌ត្នោត។ ស្លាកស្នាមអុជនេះបណ្តាលមកពីផ្សិតរាតត្បាតនៅពេលស្លឹកជំពេញរូបរាង ប៉ុន្តែស្លឹកនៅខ្ចីនៅឡើយ។ នៅលើស្លឹកខ្ចី ការរាតត្បាតនៃជំងឺធ្វើឱ្យមានស្លាកស្នាម អុចពណ៌ខ្មៅនៅរាយប៉ាយនិងរាលដាលនៅពេញផ្ទៃស្លឹកហើយធ្វើឱ្យស្លឹកជ្រីវជ្រួញ។ នៅលើស្លឹកចាស់ មានស្នាមដំបៅ (lesion) ជាចំណុចតូចៗមានព៌ណត្នោត។ ជំងឺនេះត្រូវបានឃើញកើតមាននៅលើកូនកៅស៊ូស៊ីដលីង ច្រើនជាងកូនកៅស៊ូបំប៉ៅ។ នៅលើដើមកៅស៊ូចាស់ ជំងឺភ្នែកចាប មិនឃើញកើតមានទេ ហើយក៏មិនសំខាន់នោះដែរ។



## ៣. ភ្នាក់ងារបង្កជំងឺ

ជំងឺភ្នែកចាប បង្កឡើងដោយផ្សិត *Drechslera heveae* ឬ *Helminthosporium heveae* ដែលបង្កើតនូវស្ប៉ (spores) វែងធំពណ៌ត្នោតក្រម៉ៅដែលអាចមើលឃើញដោយប្រដាប់ឆ្លុះកាន់ដៃ (hand lens)។ នៅពេលបញ្ចេញស្ប៉ គេឃើញស្ប៉ពណ៌ត្នោតស្រអាប់ជាច្រើនស្ថិតនៅចំកណ្តាល នៃស្នាមអុជនៅផ្នែកខាងក្រោមផ្ទៃស្លឹក។ ស្ប៉ទាំងនោះនឹងបែកសាយភាយចេញដោយខ្យល់នាំទៅរយៈចម្ងាយឆ្ងាយ។

ទឹកភ្លៀង សន្សើម និង ទំនាក់ទំនងពីដើមមួយទៅដើមមួយ គឺជាមូលហេតុធ្វើឱ្យស្ប៉ដាច់ចេញពីស្នាមដំបៅទៅកន្លែងផ្សេងទៀត។ កាលណាបើជំងឺនេះកើតឡើងនៅក្នុងថ្នាលបណ្តុះកូន វានឹងរាលដាលយ៉ាងឆាប់រហ័ស ហើយស្លឹកកៅស៊ូកម្រគេចផុតពីជំងឺនេះណាស់។ ក្រៅពីដើមកៅស៊ូ គេពុំឃើញមានរុក្ខជាតិផ្សេងទៀតជារុក្ខជាតិជម្រកនៃជំងឺផ្សិតនេះទេ។



# មន្ទីរពិសោធន៍ជាតិយថាប្រភេទ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

## National Specifications Laboratory of the Cambodian Rubber Research Institute

មន្ទីរពិសោធន៍ជាតិដំបូងគេដែលត្រូវបានទទួលស្គាល់តាមស្តង់ដារ
អន្តរជាតិ ISO/IEC 17025:2005 នៅឆ្នាំ២០០៨

អាសយដ្ឋាន: ភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
អ៊ីមែល: crri@camnet.com.kh
លេខទូរស័ព្ទ: 012 464 647

- ផ្តល់សេវាកម្មធ្វើតេស្ត និងផ្តល់វិញ្ញាបនបត្រគុណភាពសម្រាប់ការនាំចេញយថាប្រភេទកៅស៊ូកម្ពុជាដែលហៅកាត់ថាCSR (Cambodian Specified Rubber)
- មន្ទីរពិសោធន៍ជាតិយថាប្រភេទអនុវត្តតាមស្តង់ដារអន្តរជាតិ ISO/IEC 17025:2017 (តម្រូវការទូទៅសម្រាប់សមត្ថភាពមន្ទីរពិសោធន៍ធ្វើតេស្ត និងព្យាសកម្មឧបករណ៍) (General Requirements for the Competence of Testing and Calibration Laboratories) គ្របដណ្តប់លើវិសាលភាពតេស្តអន្តរជាតិ ISO ចំនួន៨ ចែងក្នុងស្តង់ដារ ISO 2000 អំពីយថាប្រភេទកៅស៊ូបច្ចេកទេស ដែលហៅកាត់ថាTSR (Technically Specified Rubber)
- ទទួលស្គាល់ជាមន្ទីរពិសោធន៍តំបន់ដោយសមាគមកៅស៊ូអន្តរជាតិ(IRA) សម្រាប់កិច្ចសន្យាអន្តរជាតិអំពីកៅស៊ូ TSR
- ជាមន្ទីរពិសោធន៍យោងសម្រាប់មន្ទីរពិសោធន៍មូលដ្ឋាន(មន្ទីរពិសោធន៍ធ្វើតេស្តកៅស៊ូក្នុងស្រុក)។

## ការធ្វើតេស្តកៅស៊ូ

មន្ទីរពិសោធន៍ធ្វើតេស្តតាមវិធីតេស្តអន្តរជាតិ(ISO)ថ្មីបំផុតដើម្បីធ្វើចំណែកថ្នាក់យថាប្រភេទកៅស៊ូកម្ពុជា(CSR)រួមមាន៖ ១)ការកំណត់ភាគរយអសុទ្ធភាព(ISO 249) ២)ការកំណត់ភាគរយអាសូត(ISO 1656) ៣)ការកំណត់ភាគរយផេះ(ISO 247-1) ៤)ការកំណត់ភាគរយសារធាតុហើរ(ISO 248-1) ៥)ការកំណត់រកបំលាស់រូបដើម(ISO 2007) ៦)សន្ទស្សន៍នៃការរក្សាបំលាស់រូប(ISO 2930) ៧)ការកំណត់រកសន្ទស្សន៍ពណ៌(ISO 4660) ៨)ការកំណត់វីស្កូស៊ីធីមូនី(ISO 289-1)។

ISO 1795 - ការកិនឲ្យស្មើសាច់
Sampling and further preparative procedures



ភាគសំណាកត្រូវកិនឲ្យស្មើសាច់ចំនួន៦សា នៅសីតុណ្ហភាពធម្មតា មុននឹងកាត់យកគំរូវិភាគទៅធ្វើតេស្ត។ រូឡូមុខនិងក្រោយរបស់ឧបករណ៍វិលតាមទិសផ្ទុយគ្នាក្នុងល្បឿន ២៤ជុំ/នាទី និង៣៤/នាទី (មេគុណកកិតស្មើ១:១,៤) បង្កើតការកិតមួយធ្វើឲ្យភាគសំណាកច្របល់ស្មើសាច់ ដើម្បីទទួលបានលទ្ធផលតេស្តដែលមានសុក្រឹតភាព។

សំណាកដែលទទួលនៅមន្ទីរពិសោធន៍ ត្រូវកិនឲ្យស្មើសាច់រួចបែងចែក និងរក្សាទុករយៈពេល៦ខែ។ ទម្ងន់ភាគសំណាករក្សាទុកត្រូវមានបរិមាណគ្រប់គ្រាន់សម្រាប់ធ្វើតេស្តឡើងវិញក្នុងករណីចាំបាច់។

### ISO 1795 - ការកិនបែងចែកសំណាក
### Sampling and further preparative procedures



ការបែងចែកសំណាកសម្រាប់តេស្តនីមួយៗមានៈ

| | |
|---|---|
| • ការកំណត់ភាគរយអសុទ្ធភាព(ISO 249) | ២០-៣០ ក្រាម |
| • ការកំណត់ភាគរយអាសូត(ISO 1656) | ៥-១០ ក្រាម |
| • ការកំណត់ភាគរយផេះ(ISO 247) | ១០-២០ ក្រាម |
| • ការកំណត់ភាគរយសារធាតុហើរ(ISO 248-1) | ២០-៣០ ក្រាម |
| • ការកំណត់បំលាស់រូបដើម(ISO 2007) | ២០-៣០ ក្រាម |
| • សន្ទស្សន៍នៃការរក្សាបំលាស់រូប(ISO 2930) | ២០-៣០ ក្រាម |
| • ការកំណត់រកសន្ទស្សន៍ពណ៌(ISO 4660) | ២០-៣០ ក្រាម |
| • ការកំណត់វីស្កូស៊ីធីមូនី(ISO 289-1) | ២០-៣០ ក្រាម |

### ISO 247 - ការកំណត់ភាគរយផេះ
### Determination of ash



ក្រោមអំពើនៃកម្តៅខ្ពស់នៃឡ(៥៥០±២៥°C) សារធាតុសរីរាង្គទាំងអស់(រួមទាំងម៉ាក្រូម៉ូលេគុលកៅស៊ូធម្មជាតិ) ត្រូវបានបំប្លែងជាឧស្ម័នរួចភាយចេញអស់ លើកលែងតែសារធាតុរ៉ែត្រូវបានរងអុកស៊ីតកម្មស្ថិតក្នុងរូបភាពជាផេះ។

ដូចនេះការកំណត់បរិមាណផេះអាចឲ្យយើងដឹងថា តើកៅស៊ូត្រូវបានបញ្ចូលនូវសារធាតុបន្ទុក(ហួសកំណត់)ដែរឬទេ ក្នុងដំណាក់កាលមុន និងអំឡុងពេលកែច្នៃ។ សារធាតុបន្ទុកខ្លះមានឥទ្ធិពលអាក្រក់ចំពោះគុណភាពផលិតផលសម្រេចពីកៅស៊ូ។

### ISO 248-1 - ការកំណត់ភាគរយសារធាតុហើរ
### Determination of volatile matter content



សន្លឹកកៅស៊ូស្តើង ត្រូវបានសម្ងួតក្នុងទូកម្តៅនៅសីតុណ្ហភាព ១០៥±៥°C រហូតទទួលបានម៉ាសថេរ។ បរិមាណសារធាតុហើរគឺជាភាគរយនៃម៉ាសដែលបាត់បង់ដោយសារការសម្ងួតនេះ។

វិធីនេះកំណត់បាននូវសំណើមកៅស៊ូ ដែលបង្ហាញអំពីប្រសិទ្ធភាពនៃការសម្ងួតកៅស៊ូនៅរោងចក្រកែច្នៃ។ សំណើមខ្ពស់នាំឲ្យកៅស៊ូដុះផ្សិតអំឡុងពេលរក្សាទុកដែលជះឥទ្ធិពលមិនល្អផ្នែកអនាម័យ។ម្យ៉ាងទៀត អតិថិជនជាអ្នកខាតបង់ ដោយសារទម្ងន់សំណើមត្រូវបានគេគិតជាទម្ងន់កៅស៊ូនៅពេលជួញដូរ។

**ISO 2007 - ការកំណត់រកបំលាស់រូបដើម**
**Determination of plasticity**
**ISO 2930 - ការកំណត់សន្ទស្សន៍នៃការរក្សាបំលាស់រូប**
**Determination of plasticity retention index**



គំរូវិភាគកៅស៊ូធម្មជាតិរាងជាបន្ទះមូលសំប៉ែតកម្រាស់ ១ mm ត្រូវបានកម្តៅនៅ ១00°C (១៥ វិនាទី) រួចសង្កាត់ដោយកម្លាំង ១00 N (១៥ វិនាទី) ដោយឧបករណ៍ប្លាស្ទីម៉ែត្រវ៉ាឡាស់(ផលិតនៅប្រទេសអង់គ្លេស)។ តេស្តនេះបង្ហាញភាពធន់របស់កៅស៊ូនឹងកម្លាំងសង្កត់។

ការកំណត់សន្ទស្សន៍នៃការរក្សាបំលាស់រូប គឺការកំណត់ភាពធន់នឹងអុកស៊ីតកម្មរបស់កៅស៊ូនៅស៊ីតុណ្ហភាព(១៤0°C រយៈពេល៣0នាទី)។

**ISO 249 - ការកំណត់ភាគរយអសុទ្ធភាព**
**Determination of dirt content**



អសុទ្ធភាពក្នុងកៅស៊ូធម្មជាតិរួមមានសំបកមុខចៀរ បំណែករុក្ខជាតិ ខ្សាច់ លោហធាតុ បំណែកសម្បកកណ្តៀរ សត្វល្អិត និងសារធាតុដទៃទៀត ដែលលាងសម្អាតមិនអស់អំឡុងពេលកែច្នៃ។ កៅស៊ូធម្មជាតិត្រូវបានរំលាយក្នុងសារធាតុរំលាយសមស្របមួយ រួចច្រោះសូលុយស្យុងនោះលើសំណាញ់ដែលមានក្រឡា៤៥ µm ដើម្បីត្រងយកអសុទ្ធភាព។

អសុទ្ធភាពដែលមានទំហំធំជាង ៤៥ µm បណ្តាលឲ្យផលិតផលកៅស៊ូមានលក្ខណៈមេកានិចអន់ថយ។

**ISO 1656 - ការកំណត់ភាគរយអាសូត**
**Determination of nitrogen content**



តាមវិធី Kjeldahl កៅស៊ូត្រូវបានរំលាយក្នុងអាស៊ីតស៊ុលផួរិចខាប់នៅសីតុណ្ហភាពរំពុះ និងក្រោមជំនួយរបស់កាតាលីករគីមីមួយចំនួន ដើម្បីទទួលបានសូលុយស្យុងអាម៉ូញ៉ូម ដែលភាគច្រើនបំបែកចេញពីប្រូតេអ៊ីននៅក្នុងកៅស៊ូធម្មជាតិ។ បន្ទាប់មកអាម៉ូញ៉ូមត្រូវបានបិតដោយចំហាយទឹក និងត្រងយកដោយសូលុយស្យុងអាស៊ីតមួយរួចចុងបញ្ចប់ធ្វើអត្រាមាត្រដើម្បីកំណត់កំហាប់។

ការកំណត់អាសូតនេះគឺដើម្បីចៀសវាងការបន្លំលាយកៅស៊ូស្គមតម្លៃថោកទៅក្នុង TSR ដែលមានតម្លៃខ្ពស់ជាង។

ISO 289-1 - ការកំណត់វីស្កូស៊ីធីមូនី

Determination of Mooney viscosity



តេស្តនេះកំណត់ភាពធន់របស់កៅស៊ូនៅសីតុណ្ហភាព១០០°C នឹងកម្លាំងកកិតដោយរ៉ូទ័រវិលក្នុងល្បឿនថេរ ២ជុំ/នាទី។ វីស្កូស៊ីធីកៅស៊ូគិតជាខ្នាតមូនី(0.៨៣១ N.m) ត្រូវបានវាស់ដោយឧបករណ៍វីស្កូម៉ែត្រ (ផលិតនៅប្រទេសអង់គ្លេស)។

វីស្កូស៊ីធីមូនី គឺជាប៉ារ៉ាម៉ែត្រចំបាច់ក្នុងការធ្វើចំណែកថ្នាក់កៅស៊ូវីស្កូស៊ីធីថេរ(TSR CV)។ គេប្រើតេស្តនេះដើម្បីតាមដានការកែច្នៃផង និងនៅពេលធ្វើល្បាយ(Compounding)ដោយប្រើកៅស៊ូធម្មជាតិប្រភពចម្រុះឬទ្បូត៏ផលិតកម្មផ្សេងៗគ្នាផង។

ISO 4660 - ការកំណត់រកសន្ទស្សន៍ពណ៌

Determination of colour index



កៅស៊ូធម្មជាតិត្រូវបានរៀបចំក្នុងទំរង់ជាគ្រាប់មូលសំប៉ែតដោយការសង្កត់ពុម្ពអាលុយមីញ៉ូម។ ពណ៌របស់គ្រាប់នោះត្រូវបានកំណត់ដោយការប្រដូចនឹងពណ៌គំរូ U LOVIBOND។

គេកំណត់ពណ៌ដើម្បីបញ្ជាក់ថាកៅស៊ូ TSR ត្រូវបានកែច្នៃចេញពីទឹកជ័រស្រស់បង្កកនឹងអាស៊ីតនៅរោងចក្រក្រោមលក្ខខណ្ឌកំណត់ហើយការសម្ងួតជ័រកកត្រូវបានអនុវត្តត្រឹមត្រូវ ដោយមិនប្រើកម្តៅហួសនិងបានសម្អាតសំណល់កៅស៊ូអស់ពីធុងសម្ងួត។ ម្យ៉ាងទៀត កៅស៊ូថ្លាគេប្រើសម្រាប់កែច្នៃចេញជាផលិតផលដែលថ្លា។

## ប្រវត្តិសង្ខេប

- ១៩៩៧: មន្ទីរពិសោធន៍ជាតិយថាប្រភេទបានបង្កើតឡើង និងដាក់ឲ្យដំណើរការក្រោមជំនួយឧបករណ៍របស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD) និងជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មបារាំង(CIRAD)
- ២០០២: ចាប់ផ្តើមចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិរៀបចំឡើងដោយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី(MRB)(២លើក/ឆ្នាំ)
- ២០០៤: ចាប់ផ្តើមរៀបចំតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក(៤លើក/ឆ្នាំ)
- ២០០៥: ចូលរួមក្នុងគម្រោងពង្រឹងសមត្ថភាពពាណិជ្ជកម្មអន្តរជាតិ និងចេញវិញ្ញាបនបត្រសម្រាប់កៅស៊ូកម្ពុជា(PRCC) ទទួលជំនួយបច្ចេកទេសពីអង្គការ UNIDO ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងមន្ទីរពិសោធន៍តាម ISO/IEC 17025:2005
- ២០០៨: ទទួលបានវិញ្ញាបនបត្រទទួលស្គាល់តាម ISO/IEC 17025:2005 ទទួលជំនួយបច្ចេកទេស និងឧបករណ៍ដោយសាជីវកម្មជប៉ុនដើម្បីអភិវឌ្ឍន៍ក្រៅប្រទេស(JODC)
- ២០០៩: ទទួលស្គាល់ដោយសមាគមកៅស៊ូអន្តរជាតិ(IRA) ជាមន្ទីរពិសោធន៍តំបន់សម្រាប់កិច្ចសន្យាអន្តរជាតិអំពីកៅស៊ូTSR
- ២០១២: ចុះបញ្ជីជាមន្ទីរពិសោធន៍យោងសម្រាប់ផលិតផលកៅស៊ូដោយក្រុមការងារផលិតផលកៅស៊ូអាស៊ាន(RBPWG)

